ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១០ លេខ ២ | មេសា-មិថុនា ឆ្នាំ២០០៦ | តម្លៃ ១.៥០០៛

## ការវាយតំលៃភាពក្រីក្រនៅកម្ពុជា ឆ្នាំ២០០៦ របស់ WB: មតិ វបសអ

វបសអ អធិប្បាយរំលែករំញែកលើចំនុចសំខាន់ៗមួយចំនួននៃការវិភាគពីការវាយតំលៃភាពក្រីក្រ និងអនុសាសន៍ខាងគោលនយោបាយស្ដីពីការអភិវឌ្ឍន៍កសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិ *



តាមការស្រាវជ្រាវរបស់ វបសអ អ្នកក្រនៅតាមជនបទ ពឹងលើធនធានធម្មជាតិកាន់តែច្រើនឡើងដើម្បីទ្រទ្រង់ជីវភាពរស់នៅពួកគេ

ការវាយតំលៃភាពក្រីក្រ នៅកម្ពុជាឆ្នាំ ២០០៦ របស់ធនាគារពិភពលោក (WB) ដែលចាប់ធ្វើឡើងនៅខែកុម្ភៈ ២០០៦ បង្ហាញថា នៅទសវត្សរ៍ចុងក្រោយនេះ កម្ពុជា បានឈានទៅមុខច្រើនក្នុងការកាត់បន្ថយភាពក្រីក្រ ដោយបានផ្ដល់សុទិដ្ឋិនិយមយ៉ាងច្រើនដល់អ្នកធ្វើផែនការអភិវឌ្ឍន៍ ។ នៅពេលជាមួយគ្នា ការវាយតំលៃក៏បង្ហាញដែរថា គំលាតរវាងទីក្រុង-ជនបទ និងរវាងអ្នកមាន-អ្នកក្រ កាន់តែរីកធំ ហើយអត្រាភាពក្រីក្រមានកំរិតខ្ពស់បំផុត នៅតាមតំបន់ជនបទឆ្ងាយៗដែលខ្វះខាតផ្លូវថ្នល់ ទីផ្សារ និងសេវាកម្មជាមូលដ្ឋាន ។ ដោយសារអ្នកក្រីក្រភាគច្រើនរស់នៅតំបន់ជនបទ ការវាយតំលៃភាពក្រីក្រ (Poverty Assessment: PA) បានរំលែករំញែកឱ្យយកការអភិវឌ្ឍន៍កសិកម្មធ្វើជាក្បាលម៉ាស៊ីនទី៣ ជំរុញកំណើនសេដ្ឋកិច្ចដោយមានសមត្ថភាពខ្ពស់ក្នុងការកាត់បន្ថយភាពក្រីក្រ[១] ។ ការរំលែករំញែកនេះ គាំទ្រដល់ការយកចិត្តទុកដាក់របស់រដ្ឋាភិបាលកម្ពុជាដែលបានកំនត់ការអភិវឌ្ឍន៍កសិកម្ម ថាជាចំនុចគន្លឹះមួយនៃយុទ្ធសាស្ត្រចតុកោណ និងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ឆ្នាំ២០០៦-១០ (National Strategic Development Plan: NSDP) ។ ក្នុងលក្ខណៈជាវិទ្យាស្ថានស្រាវជ្រាវខាងគោលនយោបាយ ដែលសិក្សាពីការអភិវឌ្ឍន៍កសិកម្ម និងជនបទ វបសអ យល់ស្រប និងគាំទ្រដល់ទិសដៅគោលនយោបាយដ៏សំខាន់នេះ[២] ។

ក្នុងអត្ថបទនេះ វបសអ ពិភាក្សាពីចំនុចសំខាន់ៗនៃការវិភាគ និងអនុសាសន៍ខាងគោលនយោបាយនៅក្នុងការវាយតំលៃភាពក្រីក្រ ស្ដីពីការអភិវឌ្ឍន៍កសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិ ។ វបសអ រំលែករំញែកថា អនុសាសន៍ខាងគោលនយោបាយក្នុងការវាយតំលៃភាពក្រីក្រត្រូវមានជាចាំបាច់ ប៉ុន្ដែនៅមិនទាន់គ្រប់គ្រាន់ទេ ដើម្បីកាត់បន្ថយភាពក្រីក្រឱ្យបានតាមគោលបំណងនៅតំបន់ជនបទ ។ វបសអ យល់ថា ការរីកលូតលាស់ពិតៗក្នុង ការអភិវឌ្ឍន៍កសិកម្ម និងការកាត់បន្ថយភាពក្រីក្រនៅជនបទត្រូវមានការកំណត់គោលដៅ និងលំដាប់អនុវត្តគោលនយោបាយឱ្យបានកាន់តែល្អ ដើម្បីជំរុញកំនើនផលិតភាព និងបង្កើតការងារ ។ ចំពោះបញ្ហា

* អត្ថបទនេះ បរិយាយលំអិតលើមតិយោបល់ដែល វបសអ បានលើកឡើងនៅពេល WB ចាប់ផ្ដើមធ្វើការវាយតំលៃភាពក្រីក្រនៅកម្ពុជាឆ្នាំ២០០៦ ។ ការអធិប្បាយនេះ សង្កត់ធ្ងន់ពីសារៈសំខាន់នៃការអភិវឌ្ឍន៍កសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិក្នុងជំហានបន្ទាប់នៃការអភិវឌ្ឍន៍កម្ពុជា ព្រមទាំងតំរូវការវិធីសាស្ត្រថ្មីមួយ ដើម្បីគាំទ្រដល់ការកសាងសមត្ថភាពនៅមូលដ្ឋានតាមរយៈភាពជាដៃគូរបស់កម្ពុជា សំរាប់ការពិនិត្យតាមដាន វាយតំលៃ និងការស្រាវជ្រាវពីភាពក្រីក្រ ។

### មាតិកា

ការវាយតំលៃភាពក្រីក្រនៅកម្ពុជា........................................1
លទ្ធផលសេដ្ឋកិច្ចនៃបំរែបំរួលការប្រើប្រាស់ដីនៅកម្ពុជា....................6
ការផ្ដល់ឥណទានដល់សហគ្រាសខ្នាតតូច និងមធ្យមនៅកម្ពុជា............9
តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស ..............................12
- ស្ថានភាពក្នុងប្រទេស..............................14
- សន្ទស្សន៍សេដ្ឋកិច្ច ..............................16
ពតិមានថ្មីៗពី វបសអ ..................................................20

គ្រប់គ្រងធនធានធម្មជាតិ វបសអ រំលេចឱ្យឃើញថា អ្នកក្រីក្រនៅជនបទពឹងផ្អែកយ៉ាងខ្លាំងលើលទ្ធភាពបានប្រើប្រាស់ធនធានធម្មជាតិ ដូច្នេះត្រូវកែលំអការគ្រប់គ្រងធនធាននេះ ដើម្បីគាំពារលទ្ធភាពបានប្រើប្រាស់វាយូរអង្វែង ។ អត្ថបទស្នើឡើងនូវយុទ្ធសាស្ត្រថ្មីមួយសំរាប់កសាងសមត្ថភាពកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កើតភាពជាដៃគូរវាងអ្នកកសាងគោលនយោបាយ និងអ្នកធ្វើផែនការរបស់រដ្ឋាភិបាលកម្ពុជា ស្ថាប័នស្រាវជ្រាវគោលនយោបាយ អង្គការសង្គមស៊ីវិលនិងវិស័យឯកជនដើម្បីធ្វើការរួមគ្នាលើការតាមដាន វាយតំលៃ និងស្រាវជ្រាវភាពក្រីក្រ ។

## វិស័យកសិកម្ម

ការកាត់បន្ថយភាពក្រីក្រ វាជាប់ទាក់ទងខ្លាំងប៉ុណ្ណោះទៅនឹងកំណើនក្នុងវិស័យកសិកម្មគឺអាស្រ័យលើកិរិតដែលរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍អន្តរជាតិ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធសំខាន់ៗឯទៀត រួមទាំងវិស័យឯកជនផងអាចសហការគ្នា ផ្តល់ការគាំទ្រកាន់តែចំគោលដៅល្អដល់កសិករតូចតាច ។ ការគាំទ្រទាំងនេះមានជាអាទិ៍ ១) បង្កើនសុវត្ថិភាពកាន់កាប់ដីធ្លី និងលទ្ធភាពប្រើប្រាស់ធនធានធម្មជាតិ ២) ធ្វើការគ្រប់គ្រងធនធានទឹកឱ្យកាន់តែមានប្រសិទ្ធភាព ៣) ដករបាំងដែលរារាំងប្រសិទ្ធភាពទីផ្សារ ៤) ធ្វើឱ្យសំបូរឡើងនូវឥណទានមានការប្រាក់ទាប និង ៥) កសាងសេវាកម្មផ្សព្វផ្សាយបច្ចេកទេសឱ្យបានកាន់តែល្អដើម្បីបង្កើនទាំងទិន្នផលមុខដំណាំ និងការចិញ្ចឹមសត្វ ។

ការវាយតំលៃភាពក្រីក្រ បានសង្កត់ធ្ងន់ថា សុវត្ថិភាពកាន់កាប់ដីធ្លីតាមរយៈប័ណ្ណកម្មសិទ្ធិ មានតួនាទីសំខាន់ក្នុងការជំរុញកសិករតូចតាចឱ្យចំនាយដើមទុនលើការកែលំអដី និងធាតុចូលកសិកម្ម ។ ការស្រាវជ្រាវថ្មីៗរបស់ វបសអ លើផលប៉ះពាល់នៃប័ណ្ណកម្មសិទ្ធិដីនៅតាមតំបន់ជនបទបង្ហាញថា ដោយសារប័ណ្ណកម្មសិទ្ធិដីជាធនធានកំរ គេគួរប្រឹងប្រែងធ្វើយ៉ាងណាឱ្យការចុះបញ្ជីដីធ្លី ជះឥទ្ធិពលបានខ្លាំងបំផុតលើភាពក្រីក្រដោយផ្តោតការងារទៅលើតំបន់នានា ដែលមានប្រជាជនក្រីក្ររស់នៅច្រើន ហើយអាចទទួលរងការគំរាមកំហែងពីពួកអ្នកខ្លាំងៗដែលចូលទៅទីនោះដោយសារដីឡើងថ្លៃ ។ ការសិក្សានេះបង្ហាញថា ផលប្រយោជន៍នៃប័ណ្ណកម្មសិទ្ធិដី (ដែលជាកិច្ចសន្យាមួយប្រភេទក្នុងសង្គម) ក៏ជាប់ទាក់ទងនឹងអភិបាលកិច្ចល្អ ដែលក្នុងនេះសិទ្ធិរបស់អ្នកមានប័ណ្ណកម្មសិទ្ធិដី ត្រូវបានការពារដោយអព្យាក្រឹត្យ និងទទួលស្គាល់នៅក្នុងតុលាការ ។

ការវាយតំលៃភាពក្រីក្រ ក៏គួសបញ្ជាក់ផងដែរពីតួនាទីសំខាន់នៃការកែលំអហេដ្ឋារចនាសម្ព័ន្ធដើម្បីបង្កើនផលិតភាព ព្រមទាំងរំលេចឱ្យឃើញថាត្រូវបង្កើនវិនិយោគសាធារណៈដើម្បីពង្រឹងសមត្ថភាពគ្រប់គ្រងទឹក តាមរយៈការស្រោចស្រពកាន់តែគ្រប់ទីកន្លែង និងការគ្រប់គ្រងកាន់តែល្អ ។ នាអនាគតដ៏ខ្លី ត្រូវធ្វើការសំរេចចិត្តសំខាន់ៗ ស្តីពីការបែងចែកធនធានដ៏កំរឱ្យមានប្រសិទ្ធភាពបំផុត ដើម្បីជួយគាំទ្រដល់គំរោងស្រោចស្រពខ្នាតតូច មធ្យម និងធំ ។ គំរោងស្រោចស្រពខ្នាតតូច អាចងាយអនុវត្ត និងគ្រប់គ្រងមានប្រសិទ្ធភាពខ្ពស់ជាងនៅមូលដ្ឋាន ដែលនៅទីនោះមូលធនសង្គមអាចជួយឱ្យកសិករនៅក្បែរខាងគ្នា អាចរួមសហការកាន់តែងាយស្រួលលើការគ្រប់គ្រងទឹក ។ គំរោងខ្នាតធំក៏អាចមានប្រសិទ្ធភាពដែរ ដោយជួយជំរុញកំណើនផលិតកម្ម ប៉ុន្តែត្រូវមានប្រើមូលធនបែបស្ថាប័នច្រើនក្នុងទំរង់ជាស្ថាប័នរដ្ឋ និងការវិនិយោគហិរញ្ញវត្ថុ ។

ថ្វីបើសុវត្ថិភាពកាន់កាប់ដីធ្លី និងការកែលំអការគ្រប់គ្រងធនធានទឹកសំខាន់ខ្លាំងក្តី ប៉ុន្តែការស្រាវជ្រាវរបស់ វបសអ បង្ហាញថា កត្តាទាំងនេះជួយកាត់បន្ថយភាពក្រីក្របានប្រសើរបំផុត បើសិនជាមានឥណទានមានការប្រាក់ទាប សមាគមកសិករ សេវាកម្មផ្សព្វផ្សាយបច្ចេកទេស និងទីផ្សារកាន់តែល្អ ។ ការស្រាវជ្រាវរបស់ វបសអ បង្ហាញថា ប្រហែល ៨៥-៩០% នៃការវិនិយោគក្នុងវិស័យកសិកម្ម និងសហគ្រាសខ្នាតមីក្រូ តូច និងមធ្យម ត្រូវបានធ្វើឡើងដោយធនធានផ្ទាល់ខ្លួន ក្រៅពីនេះ គឺជាកំចីពីគ្រួសារ និងមិត្តភក្តិ ។ ក្នុងចំណោមអ្នកក្រីក្រ ហិរញ្ញវត្ថុប្រភេទនេះបានកាត់បន្ថយបរិមាណ និងមុខសញ្ញាវិនិយោគ ជាពិសេសនៅពេលដែលអត្រាការប្រាក់នៅតែមានកំរិតខ្ពស់ ។

សមាគមកសិករ អាចផ្តល់ឱ្យកសិករតូចតាចនូវអំណាចតថ្លៃយ៉ាងល្អដើម្បីលក់ផលិតផលបានថ្លៃខ្ពស់ និងបានផលចំណេញច្រើន ។ ការសិក្សាពីការចាកផុតពីភាពក្រីក្រ (MOPS) របស់ វបសអ បង្ហាញថា កសិករតូចតាចជាច្រើនពុំមានទុនហិរញ្ញវត្ថុគ្រប់គ្រាន់ទេ ។ ជាលទ្ធផល ពួកគេត្រូវជាប់ផុងក្នុងកិច្ចសន្យាលក់ដូរមួយចំនួន ដែលបង្ខំឱ្យពួកគេលក់ផលិតផលឱ្យឈ្មួញកណ្តាល (ពាណិជ្ជករ រឺឈ្មួញ) ក្នុងកំរិតថ្លៃទាបជាងថ្លៃធម្មតាដែលអាចលក់បាននៅកសិដ្ឋាន ។

សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មងាយរកបាន និងមានប្រសិទ្ធភាពក៏សំខាន់ណាស់ដែរ ដោយកសិករជាច្រើនខ្វះចំណេះធ្វើ ពីវិធីដាំដុះល្អៗ ។ ដោយពុំមានជំនួយបច្ចេកទេសសមស្រប កសិករជាច្រើនបានធ្វើតាមគ្នាដោយខុសឆ្គងដូចជាក្នុងការប្រើប្រាស់ជីគីមី និងថ្នាំកំចាត់សត្វល្អិត ។ កសិករជាច្រើនខ្វះព័ត៌មានសំខាន់ៗពីទីផ្សារ ហើយក៏ដាំដុះមុខដំណាំដែលលក់មិនបានថ្លៃល្អ ។ ពួកគេក៏គ្មានលទ្ធភាពទទួលបានសេវាចាក់ថ្នាំការពារ និងព្យាបាលសត្វដែលមានគុណភាពល្អ និងថ្លៃថោកសមរម្យដែរ ។ ដូច្នេះត្រូវមានសេវាផ្សព្វផ្សាយបច្ចេកទេសគ្រប់គ្រងដោយថ្នាក់មូលដ្ឋានកាន់ច្រើន ដើម្បីជួយឱ្យកសិករមានចំណេះដឹង និងជំនាញធ្វើចំរុះកម្ម និងប្រពលវប្បកម្មផលិតកម្ម ។

ការសិក្សារបស់ វបសអ ស្តីអំពីការពង្រីងពង្រីកទីផ្សារសំរាប់ពោត និងសណ្តែកសៀង បង្ហាញថា កម្ពុជាមានទីតាំងភូមិសាស្ត្រល្អ ដីច្រើន និងមានជីជាតិ សំរាប់អភិវឌ្ឍន៍ដំណាំទាំងពីរ ហើយរឿងនេះបានទទួលអាទិភាពក្នុងផែនការជាតិសំខាន់ៗ ដូចជា ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចលើកទី២ (២០០១-២០០៥) និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (២០០២-២០០៤) ។ កម្ពុជាក៏ហាក់ដូចមានឧត្តមភាពខាងតំលៃដែរ បើធៀបជាមួយថៃ និងវៀតណាម ។

នាបច្ចុប្បន្ន សក្តានុពលខាងលើមិនទាន់សំរេចបានទេ ពីព្រោះមានកំហិតខាងផលិតកម្ម និងទីផ្សារ ។ កំហិតផលិតកម្មមានដូចជា កង្វះគ្រាប់ពូជមានគុណភាពល្អ បច្ចេកវិទ្យា ព័ត៌មាន និងឥណទាន ។ កំហិតទីផ្សារដូចជា កង្វះព័ត៌មានទីផ្សារ កំរៃផ្សេងៗនិងថ្លៃដឹកជញ្ជូនខ្ពស់និងទំនាក់ទំនងមិនល្អ រឺការមិនទុកចិត្តគ្នារវាងកសិករ និងអ្នកទិញ ។ ផលិតផលកសិកម្មនាំចេញភាគច្រើនជាផលិតផលមិនទាន់កែច្នៃ ព្រោះកម្ពុជាមានសមត្ថភាពកែច្នៃផលិតផលកសិកម្មតិចតួច ហើយការនាំចេញមានលក្ខណៈមិនផ្លូវការ និងត្រូវបង់កំរៃក្រៅផ្លូវការខ្ពស់នៅព្រំដែន ។ ដើម្បីសំរេចសក្តានុពល

ផលិតកម្មសណ្តែកសៀងនិងពោតបានកម្ពុជាត្រូវមានយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មមួយដែលមាន ១) ការបង្កើតសមាគមកសិករ ២) កំណែទំរង់បទប្បញ្ញត្តិច្បាប់ស្តីពីការដឹកជញ្ជូនផ្លូវគោក ៣) ការបង្កើតតំបន់អភិវឌ្ឍន៍កសិកម្មពិសេស និង ៤) ការបង្កើតក្របខ័ណ្ឌមួយសំរាប់សហគ្រាសប្រើទុនចំរុះ ដើម្បីកាត់បន្ថយគំលាតខាងបច្ចេកទេស និងហិរញ្ញវត្ថុ ។

## ធនធានធម្មជាតិ និងបរិស្ថាន

ការវាយតំលៃភាពក្រីក្រ បានគូសបញ្ជាក់ត្រឹមត្រូវពីតួនាទីដ៏សំខាន់នៃធនធានធម្មជាតិ ពិសេស ព្រៃឈើ និងធនធានជលផលនៅក្នុងយុទ្ធសាស្ត្ររកចិញ្ចឹមជីវិតរបស់គ្រួសារជាច្រើននៅជនបទកម្ពុជា ។ ការសិក្សាពីមុន និងបច្ចុប្បន្នរបស់ វបសអ ស្តីពីទំនាក់ទំនងរវាងភាពក្រីក្រ និងធនធានធម្មជាតិ បានគាំទ្រដល់លទ្ធផលរកឃើញក្នុងការវាយតំលៃភាពក្រីក្រ ។

ការស្រាវជ្រាវថ្មីៗរបស់ វបសអ ក្នុងការសិក្សាពីការចាកផុតពីភាពក្រីក្របង្ហាញថា អត្រាភាពក្រីក្រក្នុងចំណោមគ្រួសារនៅជនបទដែលពឹងផ្អែកលើធនធានទ្រព្យរួម (common property resources: CPR) ជាប្រភពចំណូលសំខាន់ គឺមានកំរិតខ្ពស់ជាងអត្រាភាពក្រីក្ររបស់គ្រួសារដែលពឹងផ្អែកជាសំខាន់លើសកម្មភាពផ្សេងទៀត (តារាង១) ។

ការស្រាវជ្រាវបែបគុណភាព ក្នុងការវាយតំលៃភាពក្រីក្រដោយមានការចូលរួម (PPA) ក៏បង្ហាញច្បាស់ដែរថា អ្នកក្រីក្រនៅជនបទមានការពឹងផ្អែកច្រើនណាស់លើធនធានធម្មជាតិ ទាំងសំរាប់ការរកចំនួល និងយុទ្ធសាស្ត្រដោះស្រាយពេលមានវិបត្តិ ។ ក្នុងន័យនេះ ធនធានទ្រព្យរួមគឺជាសំណាញ់សុវត្ថិភាពដ៏សំខាន់មួយសំរាប់អ្នកក្រីក្រ ។ ដូច្នេះត្រូវមានអភិបាលកិច្ច និងការគ្រប់គ្រងធនធានធម្មជាតិឱ្យកាន់តែមានប្រសិទ្ធភាព និងនៅគ្រប់កំរិត ដើម្បីកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។

*វិស័យនេសាទ:* ប្រជាជនកម្ពុជារាប់លាននាក់ ត្រូវពឹងផ្អែកមួយផ្នែក រឺទាំងស្រុងលើការនេសាទ ដើម្បីរកចំណូល និងបំរើការហូបចុក ។ អ្នកក្រីក្រងាយទទួលរងគ្រោះបំផុត ពីព្រោះពួកគេត្រូវពឹងផ្អែកភាគច្រើនលើតំបន់បើកឱ្យប្រើប្រាស់ជាទូទៅ និងមានលទ្ធភាពប្រើប្រាស់តែបច្ចេកទេសនេសាទខ្នាតតូចប៉ុណ្ណោះ ។

កំណែទំរង់គោលនយោបាយថ្មីៗ ដែលបានផ្ទេរសិទ្ធិគ្រប់គ្រងការនេសាទទៅឱ្យសហគមន៍មូលដ្ឋាន បានពង្រីងលទ្ធភាពជាច្រើនរបស់ពួកគេ ដើម្បីគ្រប់គ្រងធនធានរបស់គេឱ្យបានប្រសើរឡើង ។ ប៉ុន្តែផលចំណេញបានពីកំណែទំរង់នេះ គឺមិនបានចែកចាយស្មើភាពគ្នាល្អរហូតទេ ។ ឧ. ក្នុងភូមិខ្លះនៃអង្កេត PPA គ្រួសារក្រីក្របំផុតរាយការណ៍ថា ការបង្កើតសហគមន៍នេសាទ តាមពិតបានកាត់បន្ថយលទ្ធភាពរបស់ពួកគាត់ ក្នុងការប្រើប្រាស់តំបន់ដែលកាលពីមុនបើកចំហឱ្យប្រើជាទូទៅ ។ ភូមិខ្លះរាយការណ៍ថា គ្រួសារក្រីក្រមួយចំនួនមិនបានចូលក្នុងក្រុមសហគមន៍នេសាទទេ ដូច្នេះក៏គ្មានសិទ្ធិត្រួតពិនិត្យ និងប្រើប្រាស់កន្លែងនេសាទល្អៗដែរ ។

ភូមិជាច្រើនដែល វបសអ បានចុះសំភាស និងធ្វើការប្រជុំសហគមន៍ក៏រាយការណ៍ពីការធ្លាក់ចុះធនធាននេសាទគិតក្នុងមួយគ្រួសារ (តារាង២) កំនើនអ្នកនេសាទយ៉ាងច្រើន និងសកម្មភាពនេសាទច្រើនពេក ។ និន្នាការប្រែក្លាយព្រៃលិចទឹក (កន្លែងត្រីពង/កូន) នៅជុំវិញបឹងទន្លេសាបទៅជាដីកសិកម្ម ក៏ចោទបញ្ហាធ្ងន់ធ្ងរដល់សហគមន៍នេសាទក្នុងការគ្រប់

*តារាង១: សូចនាករភាពក្រីក្រ តាមរយៈប្រភពចំណូលចំបង*

| ប្រភពចំណូលចំបង | ភាគរយប្រជាជន (%) | អត្រាភាពក្រីក្រ (%) |
|---|---|---|
| ការដាំដុះ និងចិញ្ចឹមសត្វ | 27.0 | 40.4 |
| ការងារបំរើខ្លួនឯង | 17.9 | 31.5 |
| ការងារយកបៀវត្សរ៍ | 27.4 | 53.4 |
| ធនធានទ្រព្យរួម (CPR) | 22.7 | 55.2 |
| ផ្សេងទៀត | 5.0 | 26.0 |
| សរុប | 100.0 | 45.0 |

ប្រភព: ទិន្នន័យឆ្នាំ ២០០៤/០៥ បានពីបទសំភាសន៍ជាមួយ ១០០៥គ្រួសារ ក្នុង ៧ខេត្ត ក្នុងការសិក្សាពីការចាកផុតភាពក្រីក្រ ។ ការប៉ាន់ស្មានភាពក្រីក្រ ផ្អែកលើបន្ទាត់ក្រីក្រជាតិ

គ្រងធនធានដែលអាចកកើតឡើងវិញនេះឱ្យមានចីរភាពដែរ ។

ប្រជាជនក្រីក្រជាច្រើន ដែលពឹងផ្អែកលើការនេសាទដើម្បីចិញ្ចឹមជីវិត ក៏ត្រូវពឹងផ្អែកលើឥណទានឯកជនមានការប្រាក់ខ្ពស់ ដើម្បីដោះស្រាយការរស់នៅដែរ ។ ជារឿយៗពួកគេត្រូវខ្ចីលុយ រឺសំភារៈពីឈ្មួញកណ្តាល រឺអ្នកធូរធារនៅជិតខាង ក្នុងលក្ខខណ្ឌថា ត្រូវលក់ផលត្រីចាប់បានឱ្យពួកគេវិញក្នុងតំលៃថេរមួយទាបជាងថ្លៃមធ្យម ។ ដូចកសិករក្រីក្រដែលត្រូវពឹងផ្អែកម្តងម្កាលលើឥណទានពីពាណិជ្ជកររឺឈ្មួញដែរ ឥណទានឯកជនមានការប្រាក់ខ្ពស់នេះតែងរារាំងគ្រួសារនេសាទក្រីក្រ ក្នុងការធ្វើវិនិយោគផ្សេងៗ និងកែលំអជីវភាពរបស់ខ្លួន ។

*វិស័យព្រៃឈើ:* ធនធានព្រៃឈើ ក៏ដើរតួសំខាន់ក្នុងជីវភាពរស់នៅរបស់ប្រជាជនមួយភាគធំដែរ ។ឧ. គ្រួសារអ្នកទីក្រុងនៅតែប្រើអុសសំរាប់ចំអិនអាហារ រីឯគ្រួសារជនបទប្រើប្រាស់ផលព្រៃឈើសំរាប់បំរើការច្រើនមុខ និងរកចំណូល ។ ថ្វីបើព្រៃឈើនៅមានច្រើនពាសពេញកម្ពុជា ប៉ុន្តែក្នុងការសិក្សាថ្មីៗរបស់ វបសអ មានប្រជាជនរាយការណ៍ពីការថយចុះរបាយ និងគុណភាពធនធានព្រៃឈើក្នុងតំបន់របស់ពួកគេ (តារាង២) ។

ដូចមានរៀបរាប់ខាងលើការស្រាវជ្រាវថ្មីៗរបស់ វបសអ បង្ហាញថា អ្នកក្រីក្រពឹងផ្អែកខ្លាំងជាងគេ លើធនធានព្រៃឈើដើម្បីទ្រទ្រង់ជីវភាព ។ អ្នកក្រីក្រ និងអ្នកក្របំផុត ក៏ដូចជាក្រុមងាយរងគ្រោះឯទៀត (ឧ. ស្ត្រីមេម៉ាយ) ជារឿយៗខ្វះខាតធនធានដើម្បីដាំដុះ រឺធ្វើនេសាទ ឱ្យមានប្រសិទ្ធភាព ។ ជាលទ្ធផល ពួកគេតែងប្រើប្រាស់ធនធានព្រៃឈើជាច្រកចុងក្រោយសំរាប់ដោះស្រាយអាហារ និងផលិតផលផ្សេងទៀត ។ បើសិនគ្មានលទ្ធភាពប្រើប្រាស់សំណាញ់សុវត្ថិភាពនេះទេ ពួកគេពិបាកនឹងគេចផុតណាស់ពីការធ្វើចំណាកស្រុក ។

ក្នុងបរិបទនេះ សំនួរចោទឡើងគឺ តើព្រៃឈើអាចរួមចំនែកប៉ុណ្ណាក្នុងការកាត់បន្ថយភាពក្រីក្រ ដោយមានចីរភាព ។ នាបច្ចុប្បន្ន ការគ្រប់គ្រងព្រៃឈើនៅមូលដ្ឋាន ហាក់ដូចធូររលុងណាស់ ។ ប្រជាជនមូលដ្ឋានច្រើនប្រើប្រាស់ព្រៃឈើជាធនធានបើកទូលាយ ដោយមានការគ្រប់គ្រងជាផ្លូវការតិចតួចលើការទាញយកធនធាន ។ ប៉ុន្តែវិស័យព្រៃឈើត្រូវមានការគ្រប់គ្រង និងអភិបាលកិច្ចមានប្រសិទ្ធភាព និងមានសហគមន៍មូលដ្ឋានចូលរួម (មិនមែនមានត្រឹមសហគ្រាសពាណិជ្ជកម្មធំៗនោះទេ) ដោយបានចូលរួមដោយផ្ទាល់ក្នុងការធ្វើសេចក្តីសំរេចចិត្តផង ។ សិទ្ធិកាន់កាប់ និងប្រើប្រាស់ព្រៃឈើ ត្រូវតែបញ្ជាក់ច្បាស់ និងមានការធានាត្រឹម

*តារាង២: ការយល់ឃើញនៅមូលដ្ឋានពីនិន្នាការអាចរកបានផលិតផលជ្រើសរើសមួយចំនួនពីធនធានទ្រព្យរួម (CPR) រវាងឆ្នាំ១៩៩៨ និង ២០០៤/០៥*

| ផលិតផល CPR | កើនខ្លាំង | កើនបន្តិច | នៅដដែល | ចុះបន្តិច | ចុះខ្លាំង |
|---|---|---|---|---|---|
| អុសដុត | 0% | 1% | 22% | 26% | 51% |
| ឈើ | 0% | 1% | 4% | 9% | 86% |
| ត្រី | 0% | 1% | 1% | 15% | 83% |
| ឫស្សី/ផ្តៅ | 0% | 0% | 19% | 23% | 58% |
| ផ្លែឈើ/បន្លែ | 1% | 9% | 27% | 33% | 30% |
| សត្វព្រៃ | 0% | 0% | 2% | 9% | 89% |
| ជ័រឈើ | 0% | 1% | 2% | 19% | 78% |

ប្រភព: ទិន្នន័យឆ្នាំ ២០០៤/០៥ បានពីសំភាសន៍ ១០០៥គ្រួសារ ក្នុង ៧ខេត្ត ក្នុង MOPS

ត្រូវ ។ ការស្រាវជ្រាវរបស់ វិបសអ ក៏បង្ហាញថា ប្រជាជនមូលដ្ឋានត្រូវមានលទ្ធភាពប្រើប្រាស់ទីផ្សារល្អប្រសើរ និងមានសិទ្ធិធ្វើពាណិជ្ជកម្មលើផលិតផលព្រៃឈើ ។បញ្ហាទាំងនេះគួរមានអាទិភាពខ្ពស់ក្នុងការអនុវត្តន៍ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ និងកម្មវិធីខាងធនធានធម្មជាតិនិងបរិស្ថាន ។

## ការកសាងសមត្ថភាព និងភាពជាដៃគូនៅមូលដ្ឋានសំរាប់ការពិនិត្យតាមដាន វាយតំលៃ និងស្រាវជ្រាវពីភាពក្រីក្រ

ការវាយតំលៃពីភាពក្រីក្រ ក៏មានកិច្ចពិភាក្សាពីសារៈសំខាន់នៃការបង្កើនប្រសិទ្ធភាពជំនួយ និងការកសាងសមត្ថភាពនៅមូលដ្ឋានសំរាប់ការកាត់បន្ថយភាពក្រីក្រ ។ ដោយសារកម្ពុជាមានបទពិសោធន៍ជាមួយជំនួយអភិវឌ្ឍន៍អន្តរជាតិជាងមួយទសវត្សរ៍មកហើយ វិបសអ យល់ថា ត្រូវតែពិចារណាពីសំនួរគន្លឹះមួយៈ តើអ្វីទៅជាការកសាងសមត្ថភាព និងតើវាមានន័យយ៉ាងណាចំពោះកម្មវិធីអភិវឌ្ឍន៍ និងការរចនាតាក់តែង ការគ្រប់គ្រង និងការផ្តល់ធនធានដល់គំរោង? រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានាត្រូវពិចារណាឡើងវិញជាបន្ទាន់ពីរឿងនេះ ។ ការវាយតំលៃភាពក្រីក្របានសង្កត់ធ្ងន់យ៉ាងត្រឹមត្រូវពីតំរូវការ ការតាំងចិត្តកាន់តែមាំខាងនយោបាយ ការបង្កើនប្រសិទ្ធភាពនៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងការសំរបសំរួលជាមួយម្ចាស់ជំនួយ ។ ប៉ុន្តែមានបញ្ហាបង្កប់ដ៏សំខាន់មួយគឺ មិនទាន់មានជំហរ រឺការតាំងចិត្តស្របគ្នាទេ ពីអត្ថន័យពិតប្រាកដនៃការកសាងសមត្ថភាពនៅមូលដ្ឋាន និងពីវិធីដើម្បីសំរេចការងារនេះ ជាពិសេសការរចនាតាក់តែង និងការអនុវត្តន៍យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ។

ផ្អែកលើការស្រាវជ្រាវថ្មីៗពីភាពក្រីក្ររបស់ វិបសអ និងបទពិសោធន៍ក្នុងការបង្កើតគំរោងវាយតំលៃពីភាពក្រីក្រ វិបសអ ស្នើអោយបង្កើតភាពដៃគូរវាងស្ថាប័នកម្ពុជា ទាំងខាងរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ដើម្បីធ្វើការរួមគ្នាវាយតំលៃ វិភាគ និងពិនិត្យតាមដានភាពក្រីក្រនៅកម្ពុជា ។ សម្ព័ន្ធដៃគូនេះ នឹងជួយជាមតិដោយផ្ទាល់ដល់យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និងការកសាងគោលនយោបាយ ព្រមទាំងផ្តោតការយកចិត្តទុកដាក់លើការកសាងសមត្ថភាពពិតៗនៅមូលដ្ឋាន សំរាប់ការស្រាវជ្រាវពីភាពក្រីក្រ និងការកសាងគោលនយោបាយ ។ការងារមួយដែលត្រូវគិតគូរឡើងវិញគឺ តួនាទីនៃជំនួយបច្ចេកទេសដែលមានការកសាងសមត្ថភាពស្ថាប័នរយៈពេលវែង និងស៊ីជំរៅ និងដែលគួរប្រើប្រាស់អ្នកជំនាញការបានជ្រើសសំរាំងឱ្យមានសមត្ថភាព និងការតាំងចិត្តក្នុងការផ្ទេរជំនាញ និងបំផុសទេពកោសល្យរបស់ជនកម្ពុជា ។

*គោលដៅសំខាន់ៗ និងផលិតផល:* សម្ព័ន្ធដៃគូនៅកម្ពុជាសំរាប់ការតាមដានវាយតំលៃ និងស្រាវជ្រាវពីភាពក្រីក្រ អាចដើរតួនាទីពាក់ព័ន្ធគ្នាពាសំខាន់ៗ:

- ពិនិត្យតាមដានការរីកចំរើនក្នុងដំណើរការកាត់បន្ថយភាពក្រីក្រ និងផលប៉ះពាល់លើគោលនយោបាយពាក់ព័ន្ធ ដោយធៀបនឹងគោលដៅជាយុទ្ធសាស្ត្រធំៗ និងកំរិតគោលតាមវិស័យនៃគោលដៅអភិវឌ្ឍន៍សហសវត្សរ៍របស់កម្ពុជា (CMDG) និងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ តាមរយៈការចងក្រងទិន្នន័យសេដ្ឋកិច្ច-សង្គមកិច្ច ឱ្យបានទៀងទាត់ និងគួរទុកចិត្ត ។
- វាយតំលៃលើយុទ្ធសាស្ត្រក្នុងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ការឆ្លើយតប និងផលប៉ះពាល់ខាងគោលនយោបាយ
- ធ្វើការស្រាវជ្រាវខាងគោលនយោបាយទៅតាមតំរូវការនៅមូលដ្ឋានលើគ្រប់ចំនុចសំខាន់ៗ នៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ នៅក្នុងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ (ឧ. ការអភិវឌ្ឍន៍កសិកម្ម ការគ្រប់គ្រងធនធានធម្មជាតិ អភិបាលកិច្ច កំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ សុខភាពនិងការអប់រំ ម៉ាក្រូសេដ្ឋកិច្ច ពាណិជ្ជកម្ម និងការអភិវឌ្ឍន៍វិស័យឯកជន) ។

សំខាន់ជាងនេះទៅទៀត ចំពោះស្ថាប័នរដ្ឋ និងស្ថាប័នស្រាវជ្រាវឯករាជ្យ សម្ព័ន្ធដៃគូអាចជាយានសំរាប់ការកសាងក្នុងរយៈពេលវែងនូវជំនាញ និងសមត្ថភាពស្ថាប័ន ដើម្បីធ្វើការពិនិត្យតាមដាន វាយតំលៃ និងស្រាវជ្រាវពីភាពក្រីក្រ ។វិធីសាស្ត្រនេះអាចជួយបំពេញបន្ថែមលើការងាររបស់រដ្ឋាភិបាល ដើម្បីធានាឱ្យមានទិន្នន័យសេដ្ឋកិច្ច-សង្គមកិច្ចគួរទុកចិត្ត និងការរចនាតាក់តែងការស្រាវជ្រាវខាងគោលនយោបាយ តាមវិស័យ ដើម្បីគាំទ្រយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ។

*តួនាទី និងដំណើរការ:* តួនាទី និងមុខងារជាក់លាក់នៃសម្ព័ន្ធដៃគូ និងស្ថាប័នដៃគូនីមួយៗ ត្រូវតែគិតគូរយ៉ាងប្រយ័ត្នប្រយែងដើម្បីធានាថា វាសមស្រប និងអាចធ្វើបាន ។ តួនាទីខ្លះ ដូចជារបស់ក្រសួងផែនការ និងវិទ្យាស្ថានជាតិស្ថិតិដែលនៅក្រោមឱវាទ គឺមានលក្ខណៈច្បាស់លាស់និងបំពេញបានយ៉ាងសក្តិសិទ្ធិហើយតាមរយៈច្បាប់ស្ថិតិឆ្នាំ២០០៥ ផែនការគោលខាងស្ថិតិ (SMP) អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ២០០៤ (CSES) និងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ។ ទោះសំរេចបានដូច្នេះក្តី ក៏ការវាយតំលៃពីភាពក្រីក្រ បានសន្និដ្ឋានថា បើសិនចង់ឱ្យតួនាទីទាំងនេះអនុវត្តបានកាន់តែសក្តិសិទ្ធិថែមទៀត ត្រូវមានការផ្តល់មូលនិធិពេញលេញសំរាប់ការកសាងសមត្ថភាពស្នូលផ្នែកស្ថិតិ និងដំណើរការប្រមូលទិន្នន័យសំខាន់ៗ ដូចមានចែងក្នុង SMP ដើម្បីធានាឱ្យមានយ៉ាងទៀងទាត់នូវទិន្នន័យសេដ្ឋកិច្ច-សង្គមកិច្ចគួរឱ្យទុកចិត្ត ។

សមាសភាពដៃគូ និងតួនាទីជាក់លាក់របស់ពួកគេ អាចកំណត់ទៅបានតែនៅក្រោយពេលបានកំនត់ច្បាស់ពីអាទិភាពនៃការងារពិនិត្យតាមដានវាយតំលៃ និងស្រាវជ្រាវ សំរាប់ CMDG និងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ។ ក្នុងនេះ អាទិភាពមួយគឺការប្រមូលជាប្រចាំ និងការវាយតំលៃទិន្នន័យស្ថិតិ ដែលត្រូវជាប់ទាក់ទិនជាសំខាន់នឹងប្រភេទសូចនាករដែលគេចង់បាន។ ក្នុងវិស័យខ្លះ ដូចជាការថែទាំសុខភាព និងអប់រំ ការកំណត់

សូចនាករសមស្របអាចងាយធ្វើ ហើយស្ថាប័នពិនិត្យតាមដានដែលមានសក្តានុពលគ្រប់គ្រាន់ ក៏មានរួចជាស្រេចដែរ ។

ម្យ៉ាងទៀត វបសអ អាចដើរតួនាទីកាន់តែមានប្រយោជន៍ក្នុងការវិភាគលើការពិនិត្យតាមដានភាពក្រីក្រ ដែលជាប់ទាក់ទងនឹងកម្មវិធីស្រាវជ្រាវរយៈពេលវែង ដោយមានរបាយការណ៍ទៀងទាត់ ។ ឧទាហរណ៍ៈ ឆ្លងតាមលទ្ធផលនៃការងារថ្មីៗក្នុងការសិក្សាពីការចាកផុតពីភាពក្រីក្រ (MOPS) ការស្រាវជ្រាវ PPA នៅតំបន់ទន្លេសាប និងគំរោងចុះបញ្ជីដីធ្លី វបសអ អាចកំនត់បាននូវភូមិ រឺកន្លែងមួយចំនួននៅតាមជនបទ និងទីក្រុង សំរាប់ធ្វើជាមូលដ្ឋាននៃអង្កេតគ្រួសារ ។ អង្កេតបែបនេះ អាចប្រើប្រាស់វិធីសាស្ត្របែបបរិមាណ និងការវាយតំលៃបែបគុណភាព (ឧ. MOPS) ដោយប្រើប្រាស់វិធីសាស្ត្រមានការចូលរួម (ឧ. PPA) ។ នៅពេលកំនត់គំរិតគោលបានហើយ ក្រុមអ្នកស្រាវជ្រាវអាចត្រលប់ទៅកន្លែងនោះវិញជាទៀតទាត់ អាចក្នុងមួយឆ្នាំម្តង រឺពីរឆ្នាំម្តង ដើម្បីធ្វើអង្កេតដដែលនេះទៀត ។ ជារួម វិធីសាស្ត្រនេះមានលំនាំដូច MOPS ដែរ តែមានប្រសិទ្ធភាព និងរលូនជាង ព្រោះរចនាតាក់តែងឡើងនៅមូលដ្ឋាន ដោយរួមសហការជាមួយពួកដៃគូពិនិត្យតាមដាន ។

ក្នុងសេណារីយ៉ូនេះ វិជ្ជាស្ថានជាតិស្ថិតិ អាចធ្វើអង្កេតគ្រួសារបានយ៉ាងល្អ ដោយមានការជួយមតិពី វបសអ និងស្ថាប័នដទៃទៀតបើសិនមានតំរូវការ ដើម្បីទទួលបានលទ្ធផលកាន់តែមានប្រយោជន៍ ដូចជាការជួយកសាងសមត្ថភាពរចនាតាក់តែងគំរោង និងធ្វើវិភាគ នៅវិជ្ជាស្ថានជាតិស្ថិតិ ។ វបសអ ក៏អាចធ្វើការជាមួយវិទ្យាស្ថានឯទៀតលើការរចនាតាក់តែង ការអនុវត្តន៍ និងការវិភាគ ការងារស្រាវជ្រាវគំរិតគោលបែបគុណភាពដែរ ។ ឧទាហរណ៍ ជាការចាប់ផ្តើម គេអាចជ្រើសយកភូមិមួយចំនួនក្នុង MOPS និង PPA ដោយអាចចាត់ឱ្យស្ថាប័ន ផ្សេងគ្នា ត្រូវទទួលខុសត្រូវលើការងារអង្កេតជាបន្តបន្ទាប់នៅក្នុងកន្សោមភូមិខុសៗគ្នា ប៉ុន្តែដោយប្រើវិធីសាស្ត្រ និងការត្រួតពិនិត្យគុណភាពដូចៗគ្នា ។ សំរាប់វិធីសាស្ត្រនេះ ជំរើសដូចគ្នានូវសូចនាករសំខាន់ៗ គឺជាលក្ខខណ្ឌគ្រឹះត្រូវបំពេញ ហើយវាអាចអំណោយផលដល់ការកសាងសមត្ថភាពរយៈពេលវែង សំរាប់ស្ថាប័នដៃគូ ដោយត្រូវប្រើជំនាញការខាងក្រៅតែនៅពេលមានការចាំបាច់ប៉ុណ្ណោះ ។

បញ្ហាគួរដោះស្រាយមួយទៀត ក្នុងការរចនារៀបចំសម្ព័ន្ធដៃគូនេះ គឺការកំនត់តំលៃនៃការកាត់បន្ថយភាពក្រីក្រ រួមទាំងលទ្ធផលនៃ CMDG ផង ។ ក្នុងនេះ តើត្រូវចំណាយអស់ប៉ុន្មានដើម្បីឱ្យសូចនាករនៃភាពក្រីក្រសំខាន់ៗ កើនដល់គំរិតជាក់លាក់ណាមួយ? ហើយនៅពេលតំលៃនេះកំនត់បានគួរឱ្យទុកចិត្តហើយ តើមានវិធីអ្វីកាន់តែសក្តិសិទ្ធិទេ ដើម្បីសំរេចគោលដៅទាំងនេះបាន ហើយតើវាមានផលប៉ះពាល់អ្វីខ្លះដល់ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ក្នុងការបែងចែកធនធានដ៏កំរ? នេះជាចំនុចមួយដែលវិទ្យាស្ថានស្រាវជ្រាវដូចជា វបសអ និងស្ថាប័នផ្សេងទៀតអាចធ្វើការរួមគ្នាជាដៃគូ ដើម្បីកសាងសមត្ថភាពទាំងសងខាង ។ តួនាទីជាក់លាក់នៃដៃគូឯទៀត ដូចជា ក្រុមការងារបច្ចេកទេសខាងធ្វើផែនការ និងការកាត់បន្ថយភាពក្រីក្រ (TWGPPR) និងអង្គការផ្សេងទៀតដែលមានសមត្ថភាពចូលរួមចំនែក ត្រូវមានការបញ្ជាក់ច្បាស់ ដើម្បីធានាឱ្យពួកគេក្លាយជាដៃគូអាចទទួលយកបាន និងមានប្រសិទ្ធភាព ។

*ការគ្រប់គ្រង និងធនធានៈ* សម្ព័ន្ធដៃគូខាងលើ គួរមានការទទួលខុសត្រូវចំពោះក្រសួងផែនការ និងស្ថាប័នរដ្ឋជាប់ពាក់ព័ន្ធនានា ដូចជា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ជាដើម ។ ការរៀបចំ និងការគ្រប់គ្រងសម្ព័ន្ធដៃគូនេះ គួរធ្វើឡើងដោយដៃគូនៅមូលដ្ឋានដោយមានការពិគ្រោះយោបល់ជាមួយអង្គការអភិវឌ្ឍន៍ និងអ្នកឯកទេសខាងភាពក្រីក្រ ។ ក្រុមស្នូលនៃក្រុមការងារបច្ចេកទេសខាងផែនការនិងការកាត់បន្ថយភាពក្រីក្រ (TWGPPR) អាចដើរតួជាគណៈកម្មការផ្តល់មតិ សំរាប់សម្ព័ន្ធដៃគូ ។ ម្យ៉ាងទៀត គួរបង្កើតក្រុមជំនាញផ្តល់មតិបច្ចេកទេស ដែលមានការចូលរួមពីអ្នកឯកទេសខាងពិនិត្យតាមដាន វាយតំលៃ និងស្រាវជ្រាវពីភាពក្រីក្រ ដើម្បីជួយជាមតិ និងផ្តល់ការគាំទ្រជាបន្តបន្ទាប់ ។

សម្ព័ន្ធដៃគូ គួរទទួលបានធនធានអំពី យន្តការផ្តល់ធនធានមួយមានអ្នកផ្តល់ជំនួយច្រើនចូលរួម ដែលបង្កើតឡើងជាពិសេសសំរាប់គោលដៅខាងលើ ។ យន្តការនេះអាចជាមូលនិធិអ្វីមួយ រឺជាមូលនិធិដែលមានស្រាប់ក៏បាន ។ ក្នុងនេះស្ថាប័នដៃគូមួយៗ មានភារកិច្ចគ្រប់គ្រងលើការបែងចែកធនធាន ដោយមានយន្តការទទួលខុសត្រូវខាងហិរញ្ញវត្ថុដ៏សមស្រប ។

*គោលការណ៍ជាមូលដ្ឋានសំរាប់ការរចនារៀបចំ និងអនុវត្តន៍ៈ* សម្ព័ន្ធដៃគូ គួរជាប់ទាក់ទិននឹងតំរូវការ និងស្ថានភាពកម្ពុជា ហើយរៀបចំឡើងស្របតាមគោលការណ៍នៃភាពជាម្ចាស់ ការតាំងចិត្ត និងការទទួលខុសត្រូវរបស់មូលដ្ឋាន ។ វាគួរជាកម្មវិធីរយៈពេលវែងដែលមាន គោលដៅរយៈពេលវែង ផលិតផលរយៈពេលខ្លី និងមធ្យម និងភាពទន់ភ្លន់អាចបត់បែងបានដើម្បីឆ្លើយតបនឹងបំរែបំរួលអាទិភាពជាតិ ។ វាគួរមានលក្ខណៈជាសម្ព័ន្ធដៃគូមានក្រឹត្យក្រមច្បាស់ សំរាប់អនុវត្តគោលដៅអភិវឌ្ឍន៍សហសវត្សរ៍របស់កម្ពុជា និងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិនាបច្ចុប្បន្ន និងអនាគត ។ វាគួរមានដំណាក់កាលវែងគ្រប់គ្រាន់ សំរាប់ការគិតគូររចនារៀបចំ ដើម្បីឱ្យមានភាពជាដៃគូនិងភាពជាម្ចាស់ពិតៗ មានការបញ្ជាក់ច្បាស់ពីតួនាទី ព្រមទាំងមានទំនុកចិត្តនិងកិច្ចសហការគ្នា ។

កម្មវិធី គួរផ្តោតទាំងក្នុងផ្នែកខ្លឹមសារ ធនធានមនុស្ស និងហិរញ្ញវត្ថុ លើការកសាងនិងអភិវឌ្ឍន៍សមត្ថភាពស្ថាប័ននៅមូលដ្ឋាន ។ តំរូវការ និងលក្ខណៈនៃជំនាញការបរទេសដើម្បីជួយសំរេចគោលដៅកម្មវិធី ក៏គួរកំនត់ដោយសម្ព័ន្ធដៃគូនៅមូលដ្ឋានដោយពិគ្រោះយោបល់ជាមួយអ្នកផ្តល់ជំនាញការទាំងនោះដែរ ។ ដំណើរការ សកម្មភាព និងលទ្ធផលនៃសម្ព័ន្ធដៃគូ គួរតែត្រូវបានសើរើពិនិត្យយ៉ាងទៀងទាត់ មានការចូលរួម និងមានលក្ខណៈស្ថាបនា ពីអ្នកវាយតំលៃឯករាជ្យ គណៈកម្មការជួយមតិ និងអ្នកផ្តល់ធនធានចំបងៗ ហើយលទ្ធផលនៃការវាយតំលៃ គួររាយការណ៍ជូនរដ្ឋាភិបាល ក្រុមការងារ TWGPPR និងកិច្ចប្រជុំក្រុមពិគ្រោះយោបល់ ។

សម្ព័ន្ធដៃគូបែបនេះ ជាវិនិយោគរយៈពេលវែងមួយក្នុងការកសាងសមត្ថភាពកម្ពុជា ដើម្បីវាយតំលៃភាពក្រីក្រដោយខ្លួនឯងប្រកបដោយគុណភាពខ្ពស់ និងកសាងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រជាបន្តមកទៀត ។

## កំនត់សំគាល់

១. ក្បាលម៉ាស៊ីនជំរុញកំណើន មានពីរផ្សេងទៀត គឺឧស្សាហកម្មកាត់ដេរ និងទេសចរណ៍

២. ការវាយតំលៃភាពក្រីក្រនៅកម្ពុជាឆ្នាំ២០០៦ របស់ WB ប្រើប្រាស់លទ្ធផលរកឃើញពីដំបូងនៃការសិក្សាចំបងៗពីរ ដែលបច្ចុប្បន្ននេះ វបសអ កំពុងបង្ហើយ គឺមានការសិក្សាពីការចាកផុតពីភាពក្រីក្រដោយសហការជាមួយWBនិងការសិក្សាពីភាពក្រីក្រមានការចូលរួមនៅ តំបន់ទន្លេសាប ដោយសហការណ៍ជាមួយ ADB ។

# លទ្ធផលសេដ្ឋកិច្ចនៃបំរែបំរួលការប្រើប្រាស់ដីនៅកម្ពុជា

*លោកKasper Hansen និង បណ្ឌិត តុប នេត អធិប្បាយពីគោលការណ៍ជាមូលដ្ឋានគំរូមួយកសាងឡើងដោយ ផ្នែកធនធានធម្មជាតិ និងបរិស្ថាននៃ វបសអ ដើម្បីវិភាគលទ្ធផលសេដ្ឋកិច្ចនៃការប្រែក្លាយដីព្រៃឈើនៅកម្ពុជា **

គោលដៅនៃការស្រាវជ្រាវផ្នែកនេះគឺ វាយតំលៃពីលទ្ធផលសេដ្ឋកិច្ចនៃការប្រែក្លាយដីព្រៃយកទៅប្រើការផ្សេងទៀត ។ ការងារនេះធ្វើឡើងដោយប្រៀបធៀបតំលៃសេដ្ឋកិច្ចសរុប (total economic value: TEV) នៃព្រៃធម្មជាតិ ទៅនឹងជំរើសប្រើប្រាស់ផ្សេងទៀត (ឧ. ការគ្រប់គ្រងព្រៃឈើដោយចិរភាព ធៀបនឹងចំការស្វាយចន្ទី) ។ ជាចំនែកមួយនៃការវិភាគសេដ្ឋកិច្ចពីបំរែបំរួលក្នុងការប្រើប្រាស់ដីកម្មវិធីធនធានធម្មជាតិ និងបរិស្ថាន (NRE) នៃ វបសអ បានកសាងគំរូមួយដើម្បីប្រៀបធៀបជំរើសផ្សេងៗឱ្យបានឯកភាពគ្នាល្អ ។

អត្ថបទនេះព្យាយាមពិនិត្យលំអិតពីចំនុចដែលគំរូបច្ចុប្បន្នអាចធ្វើបាន និងធ្វើមិនបាន ព្រមទាំងបង្ហាញពីការថ្លឹងថ្លែងធៀបគ្នារវាងគំរូស្តាទិកនិងគំរូឌីណាមិកដែលស្មុគស្មាញជាងតែអាចកែតំរូវជាបន្តបន្ទាប់នៅពេលទទួលបានទិន្នន័យច្រើនថែមទៀត ។

ការវិភាគនេះផ្អែកលើគំរូពីរបែប ។ គំរូទី១ វិភាគពីទិន្នផលហិរញ្ញវត្ថុនៃជំរើសប្រើប្រាស់ដីខុសៗគ្នា ដោយគណនាផលិតកម្មជាសក្តានុពលតាមរយះលំហូររំពឹងទុកនៃចំនាយ និងផលចំណេញ ។ គំរូទី២ បូកសរុបលំហូរសាច់ប្រាក់បានពីបំរើបំរាស់ដីខុសៗគ្នា ហើយវិភាគពីតំលៃបច្ចុប្បន្នសុទ្ធ (net present value: NPV) នៃបំរើបំរាស់ខុសៗគ្នានេះ ។

## ការវិភាគចំនាយនិងផលចំនេញ

ឧបករណ៍ចំបង ប្រើប្រាស់ក្នុងគំរូនេះ ដើម្បីធ្វើវិភាគលក្ខណៈសេដ្ឋកិច្ចនៃបំរើបំរាស់ដីខុសៗគ្នា គឺការវិភាគចំនាយ និងផលចំនេញ (cost-benefit analysis: CBA) ដែលមានប្រើច្រើនណាស់ក្នុងសេដ្ឋកិច្ចបរិស្ថាន និងក្នុងការវាយតំលៃពីលទ្ធភាពរស់រាននៃគំរោងវិនិយោគ ។ CBA គណនាតំលៃបច្ចុប្បន្ននៃចំណាយ និងផលចំណេញនៅក្នុងគំរោង បន្ទាប់មកកាត់កងគ្នាដើម្បីរក NPV ។ រីឯ NPV គឺជាតំលៃផលចំនេញគិតបញ្ចុះដល់បច្ចុប្បន្ន ដកនឹងតំលៃចំនាយគិតបញ្ចុះដល់បច្ចុប្បន្ន ។ គំរោងមួយអាចចាត់ថាមានចំនេញ បើសិន NPV វិជ្ជមាន ។កត្តាសំខាន់ក្នុងការគណនានេះគឺអត្រាគិតបញ្ចុះ(discount rate) ដែលគេប្រើដើម្បីគិតចំនាយ និងចំនេញទាំងអស់ មកជាតំលៃបច្ចុប្បន្នដែលអាចប្រៀបធៀបគ្នាបាន ។ ការគណនាបញ្ចុះ បានគិតបញ្ចូលក្នុងការវិភាគនូវតំលៃតាមពេលវេលានៃលុយ ដើម្បីធ្វើឱ្យតួលេខនានាអាចប្រៀបធៀបគ្នាបាន ។ គេសន្មតថា បុគ្គលម្នាក់តែងចង់បានលុយ ១ដុល្លារនៅថ្ងៃនេះ ជាជាង ១ដុល្លារនៅឆ្នាំក្រោយ ពីព្រោះ ១ដុល្លារថ្ងៃនេះអាចដាក់វិនិយោគក្នុងគំរោងអ្វីមួយទៀត ហើយនឹងមានតំលៃ ១ដុល្លារ + ការប្រាក់នៃគំរោងនោះក្នុងរយះ ១ឆ្នាំ ។ ដូច្នេះការជ្រើសយកអត្រាគិតបញ្ចុះ គឺសំខាន់បំផុតសំរាប់ CBA ពីព្រោះវាកំនត់ថា លំហូរលុយបច្ចុប្បន្ន ត្រូវមានតំលៃប៉ុន្មានធៀបនឹងលំហូរលុយនៅថ្ងៃអនាគត ។ រូបមន្តទូទៅនៃ NPV គឺះ

$$NPV = \sum_{t=0}^{n} \frac{B_t}{(1+r)^t} - \sum_{t=0}^{n} \frac{C_t}{(1+r)^t}$$

ក្នុងនេះ n គឺជាអាយុកាលគំរោង, t ជារយះពេលគិតជាឆ្នាំ, Bt ជាផលចំនេញនៅរយះពេល t, Ct ជាចំនាយនៅរយះពេល t, r ជាអត្រាគិតបញ្ចុះ, 1/(1 + r)t ជាមេគុណគិតបញ្ចុះនៅរយះពេល t, និង ∑ ជាផលបូកនៃចរន្តលុយ ។

ចំនុចសំខាន់មួយទៀតក្នុងសេដ្ឋកិច្ចបរិស្ថាន និង CBA សេដ្ឋកិច្ចគឺកត្តាខាងក្រៅ ។ ប្រព័ន្ធប្រើប្រាស់ដីអាច មានផលប៉ះពាល់រយះពេលខ្លី រឺវែង ជាវិជ្ជមាន និង/រឺអវិជ្ជមាន ទៅលើបរិស្ថាននៅជុំវិញ ដូច្នេះហើយវាមានផ្តល់ផលចំណេញ រឺបន្ទុកចំនាយបន្ថែមទៀតដល់សង្គម ។ ផលប៉ះពាល់ទាំងនេះគ្មានដាក់បញ្ចូលក្នុង CBA ហិរញ្ញវត្ថុទេ គឺមានគិតចូលតែចំណាយ និងផលចំនេញ ចំពោះបុគ្គលជាឯកជន ។ ចំនែកដ៏សំខាន់មួយនៃការវិភាគសេដ្ឋកិច្ច គឺការកំនត់តំលៃលើរាល់សេវាកម្មបានពីព្រៃឈើ និងការប្រើប្រាស់ដីផ្សេងទៀតដូចជាការប្រើប្រាស់ផល-អនុផលព្រៃឈើនៅមូលដ្ឋាន កិច្ចការពារទីជំរាល និងការទប់ទល់ការហូរច្រោះដី ។ ចំនុចនេះមានក្នុងគំរូដែលប្រើវិធី TEV ដោយក្នុងនេះ តំលៃផ្ទាល់ និងតំលៃប្រយោល គឺបានគិតបញ្ចូលនៅក្នុងការវាយតំលៃលើព្រៃឈើ និងការប្រើប្រាស់ដីផ្សេងៗទៀត (e.g. Gregersen et al. 1995) ។

## គោលការណ៍ជាមូលដ្ឋាននៃគំរូវិភាគ

គំរូវិភាគដែលបានកសាងឡើងសំរាប់គំរោង គឺជាតារាងជាប់ទាក់ទិនគ្នាមួយខ្សែដែលរៀបចំក្នុង Microsoft Excel 2003 ។ អ្នកប្រើប្រាស់អាចជ្រើសយកគំរូប្រើប្រាស់ដី៦បែបខុសៗគ្នា (ព្រៃធម្មជាតិ ព្រៃដាំ ចំការដំណាំយូរឆ្នាំ ដំណាំប្រចាំឆ្នាំ អេកូទេសចរណ៍ និងចិញ្ចឹមសត្វ) ។ ការប្រើប្រាស់ដីមួយបែបៗមានតារាងពុម្ពមួយសំរាប់បញ្ចូលទិន្នន័យ ហើយក្នុងនេះទិន្នផលត្រូវមានគំរូផ្អែកលើលក្ខណៈសំគាល់នៃប្រព័ន្ធប្រើប្រាស់ដីជាក់លាក់នីមួយៗ (ក្រាហ្វិក ១) ។

ការធ្វើគំរូទិន្នផល វាស្មុគស្មាញតិចរឺច្រើនទៅតាមប្រព័ន្ធប្រើប្រាស់ដី ។ ឧទាហរណ៍ ការធ្វើគំរូទិន្នផលមានចិរភាពបានពីព្រៃធម្មជាតិ វាស្មុគស្មាញខ្លាំង ដោយត្រូវគិតបញ្ចូលប្រភេទឈើចំរុះដែលមានអាយុកាលមិនស្មើគ្នា ។ ដូច្នេះផ្នែកខាងព្រៃធម្មជាតិនៃគំរូនេះ វាពិបាកយល់សំរាប់អ្នកប្រើប្រាស់ធម្មតា ពីព្រោះត្រូវមានចំណេះដឹងខាងបច្ចេកទេសព្រៃឈើទើបអាចក្តាប់បានពីការកសាងគំរូលូតលាស់ព្រៃឈើ ។ គួរកត់សំគាល់ដែរថា ការធ្វើគំរូទិន្នផលនេះផ្អែកលើទិន្នន័យតិចតួចដែលស្រង់បានពីឡូត៍គំរូតាងអចិន្ត្រៃយ៍

* អត្ថបទនេះ ផ្អែកលើរបាយការណ៍ធ្វើដោយក្រុមជំនាញការអាស៊ាន-ចិនខាងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច កាលពីខែតុលា ២០០១ មាន ចំណងជើងថា "ការបង្កើតទំនាក់ទំនងសេដ្ឋកិច្ចអាស៊ាន-ចិនកាន់តែជិតស្និទនៅសតវត្សរ៍ទី២១" ។

មួយចំនួនក្នុងព្រៃធម្មជាតិនៅកម្ពុជា (MAFF 2004) ។ ប៉ុន្តែគំរូនេះមានចំនុចសំខាន់មួយគឺ ទិន្នន័យដាក់ចូលអាចផ្លាស់ប្ដូរទៅតាមពេលវេលា នៅពេលមានទិន្នន័យច្រើនថែមទៀត ។ ដូច្នេះគំរូនេះមិនត្រូវសំគាល់ថាមានលក្ខណៈស្ដាទិកទេ ពីព្រោះអាចកែតំរូវតាមស្ថានភាព នៅមូលដ្ឋាន និងកែលំអទៅតាមពេលវេលា ។

*ក្រាហ្វិក១: គោលការណ៍ជាមូលដ្ឋានពីបែបបទដែលសមាសភាគផ្សេងៗនៃគំរូ ត្រូវបានតភ្ជាប់ទៅនឹង RUNFILE ស្នូលមួយ ដែលក្នុងនេះបំរែបំរួលលើការប្រើប្រាស់ដី គឺអាចកំណត់ និងវិភាគបាន*




ក្នុងទំព័រផ្សេងទៀតនៃតារាងពុម្ព ចំនាយធាតុចូល និងថ្លៃផលិតផល/ផលិតផលបន្ទាប់បន្សំ (បូកទាំងតំលៃប្រយោល) អាចដាក់បញ្ចូលបានហើយលំហូរចំនាយ/ផលចំនេញក្នុងមួយរយៈពេលជាក់លាក់មានចុះសង្ខេបក្នុងតារាងមួយ សំរាប់ការប្រើប្រាស់ដីនីមួយៗ ។ បន្ទាប់មក តារាងសង្ខេបនីមួយៗត្រូវបានតភ្ជាប់ ទៅនឹងឯកសារស្នូលមួយ ដែលក្នុងនេះការប្រើប្រាស់ដីខុសៗគ្នាអាចកំនត់ឡើងបាន ហើយ NPV អាចគណនាឡើង ដោយផ្អែកលើទិន្នន័យបានពីតារាងប្រើប្រាស់ដី ។ ការវិភាគពីសេណារីយ៉ូផ្សេងៗនៅក្នុងឯកសារស្នូលផ្អែកលើការប្រៀបធៀបកិរិតគោលមួយ កំនត់ដោយអ្នកប្រើប្រាស់ទៅនឹងជំរើសមួយកំនត់ដោយអ្នកប្រើប្រាស់ដែរ ។ គួរកត់សំគាល់ថា នេះមិនមែនជាគំរូកំនត់ច្រកប្រសើរ ដែលប្រាប់អ្នកប្រើប្រាស់ថាប្រព័ន្ធប្រើប្រាស់ដីបែបណាចំនេញបំផុតនោះទេ ។ គំរូគ្រាន់តែអាចទស្សន៍ទាយថា មានខាត/ចំនេញប៉ុន្មាននៅក្នុងបំរែបំរួលការប្រើប្រាស់ដីជាក់លាក់ណាមួយដែលកំនត់ដោយអ្នកប្រើប្រាស់ ។

## កំរិតគោល និងសេណារីយ៉ូផ្សេងទៀតក្នុងការស្រាវជ្រាវខាងធនធានធម្មជាតិ និងបរិស្ថាន (NRE)

កំរិតគោលដែលបានជ្រើសយកសំរាប់ ការស្រាវជ្រាវកំពុងដំណើរការក្នុងកម្មវិធីNRE របស់ វបសអ គឺ ព្រៃធម្មជាតិ ដែលមានប្រភេទព្រៃស្រោង ពាក់កណ្ដាលស្រោង និងល្បោះ និងដែលផ្ដល់:

*តំលៃផ្ទាល់:* អនុផលព្រៃឈើត្រូវបានវាយតំលៃតាមថ្លៃទីផ្សារ ដោយផ្អែកលើការប្រើប្រាស់ជាក់ស្ដែង ដែលរកឃើញក្នុងអង្កេតគ្រួសារ និងគិតជាតំលៃក្នុង ១ហ.ត ។

*តំលៃប្រយោល:* ព្រៃឈើផ្ដល់តំលៃប្រយោលជាច្រើននៅកំរិតមូលដ្ឋាន ជាតិ និងសាកល ។ នៅកំរិតមូលដ្ឋាន គឺមាន កិច្ចការពារទីជំរាល ការថែរក្សាដី ជំរកសត្វ និងតំលៃខាងវប្បធម៌ ។ នៅកំរិតសាកល ព្រៃឈើមានមុខងារដ៏សំខាន់ដូចជា ការស្រូបទុកកាបូន ការកាត់បន្ថយកំនើនកំដៅធាតុអាកាសសាកល ព្រមទាំងការអភិរក្សជីវចំរុះ និងហ្សែនសត្វ-រុក្ខជាតិ សំរាប់មនុស្សជំនាន់ក្រោយ ។ តំលៃទាំងនេះភាគច្រើន មិនទាន់បានសិក្សាល្អទេនៅកម្ពុជា ។ ការស្រូបទុកកាបូន និងកិច្ចការពារទីជំរាល បានកំនត់ជាតំលៃដោយផ្អែកលើការសិក្សានានា ដែលបានធ្វើឡើងនៅកន្លែងផ្សេងក្នុងតំបន់ (e.g. Brown 1997; Gou 2001) ។

*តំលៃតាមជំរើស:* ក្នុងការវិភាគនេះ គេសន្មតថា បន្ថែមលើតំលៃផ្ទាល់ និងប្រយោល ព្រៃធម្មជាតិក៏មានតំលៃសក្ដានុពលក្នុងទំរង់ជាការកាប់យកឈើដោយចិរភាព ដែលបច្ចុប្បន្នពុំមានអនុវត្តទេ ដូច្នេះហើយទើបគេចាត់ទុកវាជាតំលៃតាមជំរើស ។

ព្រៃដាំផ្សេងៗ (អាកាស្យា ដើមប្រេងខ្យល់ ម៉ៃសាក់), ចំការដំណាំយូរឆ្នាំ (កៅស៊ូ ស្វាយចន្ទី ដូងប្រេង) និងកសិកម្ម (ស្រូវ សណ្ដែកសៀង ដំឡូងឈើ ពោត) គឺជាការប្រើប្រាស់ដីរបៀបផ្សេងដែលនឹងត្រូវយកមកប្រៀបធៀបជាមួយកំរិតគោល ដោយប្រើអត្រាគិតបញ្ចុះខុសៗគ្នា (r) ក្នុងរយៈពេល ៥០ឆ្នាំ (n) ។

## ឧទាហរណ៍នៃរបៀបប្រើគំរូ

តារាង១បង្ហាញពីភាពខុសគ្នារវាងការវិភាគហិរញ្ញវត្ថុនឹងការវិភាគសេដ្ឋកិច្ច លើការកែប្រែ ព្រៃល្បោះ ១ហ.ត ទៅជាចំការដើមប្រេងខ្យល់វិញ ។ បើសិនគិតចូលតែចំនាយ និងផលចំណេញរបស់ឯកជន គឺអាជីវកម្មនេះហាក់ដូច អាចរស់រានបាន ដោយសន្មតថា អត្រាលូតលាស់ដើមឈើគឺ ១៥ម៣/ហ.ត/ឆ្នាំ ហើយចំនាយ និងផលចំណេញនានា គ្មានការប្រែប្រួល ។ ប៉ុន្តែបើសិនគិតចូល ការខាតបង់តំលៃដែលបានពីការប្រមូលអនុផលព្រៃឈើនៅមូលដ្ឋាន គំរោងដដែលបែរជាមានតំលៃអវិជ្ជមានទៅវិញ ។ ដូច្នេះគេឃើញច្បាស់ពីសារៈសំខាន់ត្រូវគិតបញ្ចូលកត្តាខាងក្រៅ ដើម្បីវាយតំលៃថា ការផ្លាស់ប្ដូរការប្រើប្រាស់ដី អាចរស់រានមានចំនេញរឺទេ សំរាប់ប្រទេសកម្ពុជាទាំងមូល ។

*តារាង១: លទ្ធផលនៃការប្រែក្លាយព្រៃល្បោះ ១ហ.ត ទៅជាចំការ ដើមប្រេងខ្យល់*

| CBA | NPV |
|---|---|
| ការវិភាគហិរញ្ញវត្ថុ | US$ 395 |
| ការវិភាគសេដ្ឋកិច្ច គិតបញ្ចូលទាំងការខាតបង់តំលៃបានពីព្រៃធម្មជាតិ | US$ -197 |

ផ្អែកលើ អត្រាគិតបញ្ចុះ ១០%

គោលការណ៍នៃការគណនាក្នុងគំរូនេះ មានចុះក្នុងក្រាហ្វិក១ ដែលបង្ហាញពីលំហូរចំនាយ និងផលចំណេញ ក្នុងមួយវដ្ដមានរយៈ ៥០ឆ្នាំ ។ ក្នុងការវិភាគ មានការកំនត់ TEV សំរាប់ការប្រើប្រាស់ដីទាំងពីរបែប ហើយគំរូនេះព្យាយាមគណនាបំរែបំរួលសុទ្ធលើតំលៃប្រើប្រាស់ និងតំលៃមិនប្រើប្រាស់ នៅពេលផ្លាស់ប្ដូរពីការប្រើប្រាស់ដីមួយបែប ទៅមួយបែបទៀត ។

ឧទាហរណ៍នេះបង្ហាញថា ចំនាយពីដំបូងក្នុងការបង្កើតចំការដើមប្រេងខ្យល់ បង្កឥទ្ធិពលអវិជ្ជមានមួយយ៉ាងធំនៅដើមគ្រា ហើយតំលៃបច្ចុប្បន្ននៃផលចំណេញបានពីការប្រមូលផល ដើមប្រេងខ្យល់ ធ្លាក់ចុះក្នុងវដ្ដនីមួយៗដោយសារការគិតបញ្ចុះ ។ លំហូរសាច់ប្រាក់គិតបញ្ចុះតំលៃទាំងអស់នេះ សរុបគ្នាមកបាន NPV=១៩៧ដុល្លារ (តារាង១) ។

## ការធ្វើតេស្តគំរូ និងការវិភាគវេទយិតភាព

គួរកត់សំគាល់ថា គំរូបង្ហាញជានិច្ចនូវគុណភាពទិន្នន័យដែលបានដាក់បញ្ចូល ។ ដូច្នេះមានការប្រឹងប្រែងយ៉ាងច្រើនក្នុងការផ្ទៀងផ្ទាត់ទិន្នន័យចុះឡើង ប៉ុន្តែបច្ចុប្បន្នមានទិន្នន័យតិចតួចណាស់ស្តីពីប៉ារ៉ាម៉ែត្រផលិតកម្ម កំរិតថ្លៃ និងចំនាយ ។ ហេតុនេះលទ្ធផលដែលគំរូរកឃើញគឺ វេទយិត (ជាប់ទាក់ទិន) ខ្លាំងណាស់ជាមួយការព្យាករណ៍ពីទិន្នផល និងការសន្មតនូវចំនាយ និងកំរិតថ្លៃ ។ នៅពេលប្រើគំរូ CBA គេត្រូវធ្វើតេស្តវាជាមួយនឹងបំរែបំរួលក្នុងប៉ារ៉ាមែត្រចំបងៗ ។ នេះហើយជាការវិភាគវេទយិតភាពដែលអាចបង្ហាញថា តើលទ្ធផលជាទូទៅជាប់ទាក់ទិនប៉ុណ្ណា ទៅនឹងបំរែបំរួលនៃប៉ារ៉ាមែត្រផ្សេងៗ ។

គួរប្រយ័ត្នប្រយែងដែរ ក្នុងការបង្កើនដែនអនុវត្តលទ្ធផល ។ ចំនាយ និងផលចំណេញប្រែប្រួលខ្លាំងពីកន្លែងមួយ ទៅកន្លែងមួយ ដោយសារកត្តាផ្សេងៗដូចជា លក្ខខណ្ឌលូតលាស់ឈើក្នុងមូលដ្ឋាន ចំនាយដឹកជញ្ជូនដែលជាប់ទាក់ទិន នឹងចំងាយផ្លូវទៅរោងអារឈើ កំពង់ផែ រឺទីផ្សារ ។ ដូច្នេះមិនគួរបង្កើនដែនអនុវត្តលទ្ធផលទៅដល់កំរិតជាតិនោះទេ ពីព្រោះក្នុងទ្រង់ទ្រាយនេះ វាអាចប្រើបានតែក្នុងតំបន់មួយតូចប៉ុណ្ណោះ ។

## កង្វះនាពេលបច្ចុប្បន្ននូវទិន្នន័យសេដ្ឋកិច្ចសំរាប់ធ្វើផែនការធនធានធម្មជាតិ

ក្នុងពេលប្រមូលទិន្នន័យ និងធ្វើគំរូ មានកង្វះខាតទិន្នន័យជាច្រើន ដូចជា ទិន្នផលរំពឹងទុកសំរាប់ប្រព័ន្ធប្រើប្រាស់ដីខុសៗគ្នា និងការសិក្សាពីតំលៃមិនប្រើប្រាស់ ។ នៅខាងក្រោមគឺជាការសង្កេត និងមតិមួយចំនួនសំរាប់ ការសិក្សានាអនាគត ។

*ព្រៃធម្មជាតិ:* ចំពោះការលូតលាស់ឈើក្នុងព្រៃធម្មជាតិនៅកម្ពុជា បច្ចុប្បន្នមានតែទិន្នន័យបានពីឡូត៍គំរូ នៅខេត្តកំពង់ធំប៉ុណ្ណោះ ។ ទិន្នន័យលូតលាស់ឈើដ៏តិចតួចដែលបានពីការវាស់វែងនៅឆ្នាំ១៩៩៨ និង ២០០០ ត្រូវបានរដ្ឋបាលព្រៃឈើបោះពុម្ពផ្សាយ (FA, 2003) ។ ប៉ុន្តែទិន្នន័យនេះធ្វើវិភាគបានតែលើកំរិតព្រៃឈើជាទូទៅប៉ុណ្ណោះ ដែលធ្វើឱ្យមានការពិបាកនឹងកែតំរូវឱ្យស៊ីគ្នាទៅនឹងរបាយប្រភេទឈើនៅតាមមូលដ្ឋាន ។ ទិន្នន័យដើម (raw data) ដែលនាំទៅដល់លទ្ធផលនេះ ក៏មិនទាន់ផ្សព្វផ្សាយដែរ ដូច្នេះគេមិនអាចធ្វើវិភាគដាច់ពីគ្នានូវកំរិតលូតលាស់នៃពូជឈើខុសៗគ្នានៅក្នុងប្រភេទព្រៃខុសៗគ្នាបានទេ ។ ដូច្នេះទិន្នន័យដែលបានផ្សព្វផ្សាយហើយ មានផលប្រយោជន៍តិចតួចណាស់ ។ ការធ្វើផែនការពីការប្រើប្រាស់ព្រៃឈើនៅមូលដ្ឋាន និងកំរិតជាតិ នឹងមានប្រសិទ្ធភាពហើយងាយស្រួល បើមានទិន្នន័យច្រើនថែមទៀតពីឡូត៍គំរូ មកធ្វើវិភាគ និងផ្សព្វផ្សាយ ។

*ក្រាហ្វិក២: លំហូរចំនាយ និងផលចំណេញគិតបញ្ចុះ នៅពេលប្រែក្លាយព្រៃល្បោះ ១ហ.ត ទៅជាចំការដើមប្រេងខ្យល់ (អត្រាលូតលាស់ឈើ ១៥ម$^3$/ហ.ត/ឆ្នាំ, អត្រាគិតបញ្ចុះ ១០%)*




*ព្រៃដាំ:* ទិន្នន័យស្តីពីពូជឈើនាំចូលដុះលូតលាស់លឿន ដូចជាដើមប្រេងខ្យល់ និងអាកាស្យា ដែលដាំនៅតាមកន្លែងខុសៗគ្នានៅកម្ពុជា ក៏មិនទាន់មានដែរ ។ ដូច្នេះសេចក្តីសំរេចចិត្តនាបច្ចុប្បន្នក្នុងការបង្កើតចំការឈើ ត្រូវផ្អែកលើការសន្មតមិនសូវរឹងប៉ឹងស្តីពីការលូតលាស់ ។ពូជឈើទាំងនេះជាទូទៅដុះលូតលាស់លឿន ប៉ុន្តែមិនលឿនដូចការរំពឹងទុកទេ ដោយសារដីមិនល្អ ការគ្រប់គ្រងមិនត្រឹមត្រូវ ដង់ស៊ីតេដាំឈើមានកំរិតទាប និងសំភារៈដាំឈើមានគុណភាពអន់ (e.g. Barr 2004) ។ ការចុះវាស់វែងដល់កន្លែង នូវលទ្ធផលជាក់ស្តែងនៃពូជឈើនាំចូលដែលដាំក្នុងចំការមានស្រាប់នៅកន្លែងខុសៗគ្នា អាចជាមធ្យោបាយងាយស្រួលដើម្បីទទួលបានព័ត៌មានពីលទ្ធផលអាចធ្វើបានពិតៗនៅតាមចំការទាំងនោះ ។

*ដំណាំយូរឆ្នាំ:* ទិន្នន័យស្តីពីទិន្នផលដំណាំយូរឆ្នាំ ច្រើនមានត្រឹមតែតួលេខប៉ាន់ស្មានរបស់ក្រុមហ៊ុន ។ ជារឿយៗ ទិន្នន័យទាំងនេះបង្ហាញពីស្ថានភាពប្រសើរបំផុតដើម្បីទាក់ទាញវិនិយោគិន ដូច្នេះគេត្រូវប្រើវាដោយប្រុងប្រយ័ត្ន ។ ទិន្នន័យស្តីពីតំលៃមិនប្រើប្រាស់នៃប្រព័ន្ធផ្សេងៗក៏ខ្វះខាតដែរ ។ឧទាហរណ៍ ចំការកៅស៊ូមានតំលៃមិនប្រើប្រាស់វិជ្ជមានច្រើនណាស់ បានមកពីឈើយឺរដែលជួយស្រូបកាបូនទុក ទប់ស្កាត់ការហូរច្រោះ និងផ្តល់សេវាកម្មជាច្រើនទៀត ។ អ្នកស្រាវជ្រាវខាងសេដ្ឋកិច្ចបរិស្ថាន គួរយកចិត្តទុកដាក់ខ្លាំងថែមទៀតពីចំនុចនេះ ។

*តំលៃប្រយោល:* នៅកម្ពុជា ការវាយតំលៃខាងបរិស្ថាននៅក្មេងខ្ចីនៅឡើយ ដូច្នេះមានកង្វះការសិក្សាអំពី តំលៃប្រយោលនៃការប្រើប្រាស់ដីខុសៗគ្នា ។ ការសិក្សាមួយចំនួនតូច បានអធិប្បាយពីតំលៃមិនប្រើប្រាស់ នៃព្រៃឈើ រឺតំបន់ការពារ (Bann 1997; Lopez 2003) ប៉ុន្តែមានការស្រាវជ្រាវតិចតួចណាស់ដើម្បីវាយតំលៃឱ្យបានជាក់ស្តែងពីតំបន់ទាំងនេះ ។ ជំហានបន្ទាប់ក្នុងសេដ្ឋកិច្ចបរិស្ថាននៅកម្ពុជា គឺគួរធ្វើការស្រាវជ្រាវច្រើនថែមទៀតពីការកំនត់តំលៃការប្រើប្រាស់ដោយប្រយោល ដើម្បីផ្តល់ជូនអ្នកកសាងគោលនយោបាយនូវតួលេខកាន់តែជាក់លាក់នៃតំលៃត្រូវបាត់បង់ក្នុងរយៈពេលវែង នៅពេលប្រែក្លាយព្រៃធម្មជាតិទៅជាដីសំរាប់ប្រើការផ្សេងទៀត ។

## គ្រោមគោលដៅបច្ចុប្បន្ន និងការដាក់ប្រើគំរូនាអនាគត

ដោយសារការធ្វើគំរូទិន្នន័យវាស្មុគស្មាញខ្លាំង និងខ្វះខាតទិន្នន័យផង ដូច្នេះគេធ្វើឱ្យគំរូបច្ចុប្បន្នមានទំរង់ងាយបត់បែនចុះឡើង ដើម្បីអាចយកទិន្នន័យដែលរកបាន មកប្រើការឱ្យបានប្រសើរបំផុត ។

*តទៅទំព័រទី ១៨*

# ការផ្ដល់ឥណទានដល់សហគ្រាសខ្នាតតូច និងមធ្យម នៅកម្ពុជា: ហេតុអ្វីធនាគារយល់ថាពិបាកអនុវត្ត?[1]

*Keith Carpenter ដោយមានជំនួយការងារពី អ៊ូច ច័ន្ទតារានី បានពិភាក្សាពីឯកសារឆ្នាំ២០០៣ នៃកម្មវិធីអភិវឌ្ឍន៍វិស័យឯកជនតំបន់ទន្លេមេគង្គ (MPDF) ស្ដីពីការផ្ដល់កំចីរបស់ធនាគារនៅកម្ពុជា **

នៅឆ្នាំ២០០៣ ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជារបស់ វិបសអ បានចុះផ្សាយអត្ថបទសង្ខេបមួយ[2] រួចហើយស្ដីពីឯកសារ MPDF ។ អត្ថបទថ្មីនេះ ពិភាក្សាពីការសិក្សារបស់ MPDF ដោយផ្ដោតលើការងារធនាគារជាក់ស្ដែង ដើម្បីផ្ដល់មតិមួយទៀត ពីកង្វះខាតការផ្ដល់ឥណទានរបស់ធនាគារនៅកម្ពុជា ថ្វីបើមានការទទួលស្គាល់ថា ត្រូវមានការផ្លាស់ប្ដូរច្រើនខាងស្ថាប័នក្ដី ។ អត្ថបទបានសន្និដ្ឋានថា មូលហេតុចំបងនៃកង្វះការផ្ដល់ឥណទានឱ្យទៅសហគ្រាសខ្នាតតូច និងមធ្យម (SMEs) គឺធនាគារអាចគ្រប់គ្រងវាបាន ។

ឯកសារ MPDF បានសរុបបញ្ហាសព្វគ្រប់ដែលធនាគារ និង SMEs នៅកម្ពុជាត្រូវប្រឈមមុខ ។ ឯកសារបានលើកពី ១៥ មូលហេតុដែលធនាគារមិនផ្ដល់ឥណទានឱ្យ SMEs និងបានផ្ដល់អនុសាសន៏ ៨ ទាក់ទិនភាគច្រើននឹងតំរូវការផ្លាស់ប្ដូរស្ថានភាពស្ថាប័ន ។ អនុសាសន៏នានាបើបានដាក់អនុវត្ត នឹងជួយឱ្យធនាគារផ្ដល់ឥណទានដល់ SMEs ក្នុងរយៈពេលវែង ។ផ្អែកលើលទ្ធផលមានចុះក្នុងការសិក្សា MPDF អត្ថបទនេះអះអាងថា ធនាគារមិនផ្ដល់ឥណទានឱ្យ SMEs ដោយសារធនាគារមិនគិតថា ការផ្ដល់ឥណទានជាការងារចំបងរបស់ខ្លួន មិនមែនដោយសារភាពទន់ខ្សោយខាងស្ថាប័នណាមួយទេ ។ លទ្ធផលនេះ ប្រហែលផុសចេញពីការយល់ឃើញរបស់ធនាគារថា ពួកគេអាចរកចំណូលបានគ្រប់គ្រាន់ពីសកម្មភាពដទៃទៀត (ដែលមិនមែនផ្ដល់ឥណទាន) ដោយមិនចាំបាច់ចូលពាក់ព័ន្ធនឹងការផ្ដល់ឥណទានឱ្យ SMEs ។

កង្វះការយកចិត្តទុកដាក់ផ្ដល់ឥណទានរបស់ធនាគារកម្ពុជា អាចមើលឃើញច្បាស់ក្នុងចំនុចមួយមានបញ្ជាក់ក្នុងការសិក្សា MPDF: កង្វះមន្ត្រីឥណទានរបស់ធនាគារ (§3.13, p. 32) ។ ធនាគារខ្លះមានបុគ្គលិកតែ ២ ទៅ ៣នាក់ប៉ុណ្ណោះ សំរាប់គ្រប់គ្រងការផ្ដល់ឥណទាន ហើយពួកគេច្រើនមានតួនាទីបន្ថែមផ្សេងទៀត ។ នៅប្រទេសភាគច្រើន ការផ្ដល់ឥណទាន គឺជាតួនាទីគន្លឹះនៃធនាគារ និងជាប្រភពចំបងនៃប្រាក់ចំណូលរបស់ពួកគេ ប៉ុន្ដែធនាគារនៅកម្ពុជា ហាក់ដូចមិនបានចំណាយធនធានដ៏ចាំបាច់ដើម្បីផ្ដល់ឥណទាន និងបង្កើនចំណូលពីការផ្ដល់ឥណទាននោះសោះ ។ ប្រតិបត្តិការធនាគារគឺការផ្ដល់ឥណទាន ហើយការផ្ដល់ឥណទានត្រូវមានការវាយតំលៃពីហានិភ័យ ដើម្បីទាមទារកំរៃឱ្យសមស្របនឹងហានិភ័យឥណទានដែលធនាគារត្រូវកត់ត្រាក្នុងតារាងតុល្យការនៅពេលមានការផ្ដល់ឥណទាន ។

អង្កេតក្រៅផ្លូវការនាពេលថ្មីៗ លើធនាគារធំៗមួយចំនួននៅភ្នំពេញស្ដីពីចំនួនមន្ត្រីឥណទានតាំងពីឆ្នាំ២០០២ បានបង្ហាញពីកំនើនគួរកត់សំគាល់ ។ ម្យ៉ាងទៀតក៏មានកំនើនសកម្មភាពផ្ដល់ឥណទានផងដែរ ។ កំណើនទាំងនេះ បង្ហាញថាធនាគារបានចាប់ផ្ដើមមានឥរិយាបថវិជ្ជមានចំពោះការផ្ដល់ឥណទានហើយ ។

## លទ្ធផលនៃការសិក្សា

ការសិក្សាMPDF កំណត់បាន ១៥ បញ្ហាដែលរារាំងការផ្ដល់ឥណទានដល់ SMEs ។ ដើម្បីធ្វើវិភាគ បញ្ហាបានចែកចេញជា ៥ ប្រភេទៈ

១. ច្បាប់: ត្រូវមានច្បាប់ រឺក្របខណ្ឌច្បាប់ថ្មី
២. រដ្ឋបាលៈ ត្រូវផ្លាស់ប្ដូររបៀបអនុវត្តច្បាប់កន្លងមក ជាជាងបង្កើតច្បាប់ថ្មី
៣. ទីផ្សារៈ ជាលទ្ធផលនៃរបៀបរៀបចំ និងដំណើរការប្រព័ន្ធហិរញ្ញវត្ថុ
៤. គោលនយោបាយឥណទានៈ គោលនយោបាយ រឺបែបបទ ដែលអនុវត្តដោយធនាគារមានការគ្រប់គ្រងល្អនៅអន្តរជាតិ ក្នុងការផ្ដល់ឥណទាន
៥. ធនាគារៈ បញ្ហាស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារក្នុងស្រុក ។

អត្ថបទនេះវែកញែកថា ប្រភេទទី៥ គឺបញ្ហាស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារក្នុងស្រុក ជាឧបសគ្គចំបងនៃការផ្ដល់ឥណទានរបស់ធនាគារនៅកម្ពុជា ។

ដោយយោងតាមប្រភេទកំនត់ខាងលើ បញ្ហានានាដែល MPDF បានរកឃើញមានរាយលំអិតក្នុងតារាង ១ ។

បញ្ហាចោទធំក្នុងលទ្ធភាពរបស់ធនាគារដើម្បីធ្វើការផ្លាស់ប្ដូរ គឺបុគ្គលិកធនាគារពុំមានការបណ្ដុះបណ្ដាលគ្រប់គ្រាន់ពី ការវិភាគ និងគ្រប់គ្រងហានិភ័យនៃការផ្ដល់ឥណទានរយៈពេលវែងដល់ SMEs (§3.3, p. 27) និងកង្វះមន្ត្រីផ្នែកឥណទាននៅក្នុងធនាគារ (§3.13, p. 32) ។ បញ្ហាមួយទៀតដែលស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារ គឺនៅក្រៅក្រុងសំខាន់ៗ SMEs មិនអាចទៅទាក់ទងធនាគារបានទេ (§3.5, p. 28) ។ ចំនុចចុងក្រោយក៏ជាឧបសគ្គចំពោះការផ្ដល់ឥណទានដែរ ប៉ុន្ដែវាមិនធ្ងន់ធ្ងរដូចចំនុចពីរខាងដើមទេ ។ ធនាគារគ្មានប្រតិបត្តិការនៅក្រៅក្រុង ពីព្រោះពួកគេយល់ថាគ្មានការចាំបាច់អ្វីទេ ។រឿងនេះបង្ហាញថា ធនាគារអាចប្រមូលបានប្រាក់បញ្ញើគ្រប់គ្រាន់នៅតាមទីប្រជុំជនធំៗ សំរាប់ដោះស្រាយតំរូវការឥណទានរបស់ខ្លួន ។ធនាគារក៏មើលមិនឃើញថាមានទីផ្សារសំរាប់ការផ្ដល់ឥណទាននៅតាមទីប្រជុំជនតូចៗ ដូច្នេះក៏មិនពង្រីកសេវាកម្មទៅកន្លែងទាំងនោះទេ ។

* Dr Keith Carpenter ជាទីប្រឹក្សាស្រាវជ្រាវ ធ្លាប់បំរើការជាមន្ត្រីជាន់ខ្ពស់ខាងធនាគារនៅអូស្ត្រាលី ឯកញ៉ា អ៊ូច ច័ន្ទតារានី ជំនួយការស្រាវជ្រាវនៅ វិបសអ ។

តារាង ១. មូលហេតុនៃកង្វះការផ្ដល់ឥណទានធនាគារដល់ SMEs

| លេខ | បញ្ហា | ប្រភេទ |
|---|---|---|
| ៣.១ | ច្បាប់មិនគ្រប់គ្រាន់ | ច្បាប់ |
| ៣.២ | ប្រព័ន្ធតុលាការទន់ខ្សោយ | រដ្ឋបាល |
| ៣.៣ | បុគ្គលិកមានការបណ្ដុះបណ្ដាលមិនគ្រប់គ្រាន់ | ធនាគារ |
| ៣.៤ | ការកំនត់ថ្លៃមិនសមស្របរបស់ធនាគារលើហានិភ័យ | គោលនយោបាយឥណទាន |
| ៣.៥ | ធនាគារមានទៅដល់តែទីប្រជុំជនសំខាន់ៗ | ធនាគារ |
| ៣.៦ | រចនាសម្ព័ន្ធលើកទឹកចិត្តនៅក្នុងធនាគារ | គោលនយោបាយឥណទាន |
| ៣.៧ | លក្ខណៈវិនិច្ឆ័យនៃកំចីអប្បបរមាសំរាប់ការផ្ដល់ឥណទានរបស់ធនាគារ | គោលនយោបាយឥណទាន |
| ៣.៨ | ដំណើរការផ្ដល់ឥណទានរបស់ធនាគារ | គោលនយោបាយឥណទាន |
| ៣.៩ | ទីផ្សារឥណទានក្រៅផ្លូវការមានប្រសិទ្ធភាពជាង | ទីផ្សារ/ធនាគារ |
| ៣.១០ | កង្វះការផ្ដល់ទុនរយៈពេលវែង | រដ្ឋបាល |
| ៣.១១ | ចំណាយខ្ពស់សំរាប់កំចីរយៈពេលវែង | ទីផ្សារ |
| ៣.១២ | ចំនូលចិត្តផ្ដល់ឥណទានឱ្យតែបុគ្គល | គោលនយោបាយឥណទាន |
| ៣.១៣ | កង្វះមន្ត្រីផ្នែកផ្ដល់ឥណទាន | ធនាគារ |
| ៣.១៤ | កង្វះស្ថាប័នមានជំនាញឯកទេសខាងផ្ដល់ឥណទាន | ទីផ្សារ |
| ៣.១៥ | ពន្ធកាត់ទុកលើទុនមកពីក្រៅប្រទេស | រដ្ឋបាល |

ចំនុចមួយទៀតដែលបានលើកនៅខាងលើថាជាបញ្ហាខាងគោលនយោបាយឥណទាន ក៏គួររំលែកញែកផងដែរ ។ ខ្លះយល់ថា កង្វះរចនាសម្ព័ន្ធលើកទឹកចិត្តនៅក្នុងធនាគារកម្ពុជា បានបង្អាក់ទឹកចិត្តមន្ត្រីឥណទានក្នុងការផ្ដល់ឥណទានយ៉ាងសកម្ម ។ ប៉ុន្តែរឿងនេះមិនសមក្លាយជាឧបសគ្គសោះ ។ ធនាគារដែលគ្រប់គ្រងបានល្អភាគច្រើនមិនផ្ដល់គ្រឿងលើកទឹកចិត្តទៅតាមទំហំកំចីដល់មន្ត្រីឥណទានទេ ។ បទពិសោធន៍រយៈពេលវែងបង្ហាញថា បើសិនផ្ដល់ប្រាក់កំរៃទៅតាមទំហំឥណទានដល់មន្ត្រីឥណទាន ធនាគារច្បាស់ជាជួបនឹងផលវិបាកក្នុងការផ្ដល់ឥណទានហើយ ។

អនុសាសន៍ក្នុងការសិក្សាMPDF អាចបែងចែកដូចក្នុងតារាង២ខាងក្រោម ។ អនុសាសន៍មួយដែលស្ថិតក្រោមសិទ្ធិអំនាចធនាគារ ដើម្បីធ្វើការផ្លាស់ប្ដូរគឺ ការបណ្ដុះបណ្ដាលបុគ្គលិកពីការវាយតំលៃលើហានិភ័យ ។ រឿងនេះ ពាក់ព័ន្ធនឹងការរកឃើញថា បុគ្គលិកធនាគារពុំមានការបណ្ដុះបណ្ដាលគ្រប់គ្រាន់ ។បើធនាគារចង់បង្កើនការផ្ដល់ឥណទាន គឺត្រូវកែលំអជំនាញវាយតំលៃហានិភ័យ ហើយរឿងនេះធនាគារអាចគ្រប់គ្រងបាន ដូចដែលការសិក្សាបានបង្ហាញ ។

អត្រាចំណេញលើឥណទាននៅកម្ពុជា ខ្ពស់ខ្លាំងណាស់ បើធៀបនឹងស្តង់ដារអន្តរជាតិ ។ ការសិក្សាបង្ហាញថា ចំណាយលើមូលនិធិដើមត្រឹមតែ ៦% ក្នុងមួយឆ្នាំ បែរជាមានអត្រាលើកំចីរហូតដល់ ១៩% ដែលផ្ដល់អត្រាចំនេញលើឥណទានរហូតដល់ ១៣% ។អត្រាចំណេញបែបនេះ ហួសពីគ្រប់គ្រាន់ក្នុងការទូទាត់ចំនាយផ្សេងៗ លើការផ្ដល់ឥណទាន ព្រមទាំងមានផ្ដល់ប្រាក់ចំណេញសមរម្យ និងប្រាក់បំរុងសំរាប់រ៉ាប់រងកំចីទារមិនបានផង ។ ដូច្នេះរឿងអត្រាការប្រាក់មិនគ្រប់គ្រាន់ វាមិនមែនជាហេតុផលចំបងនៃកង្វះការផ្ដល់ឥណទានរបស់ធនាគារ ទៅឱ្យ SMEs នោះទេ ។

## អាជីវកម្មធនាគារ

ធនាគារ គឺជាឈ្មួញកណ្ដាលខាងហិរញ្ញវត្ថុ ដោយខ្ចីប្រាក់ពីភ្នាក់ងារសេដ្ឋកិច្ចមានមូលនិធិលើស ហើយផ្ដល់កំចីទៅឱ្យភ្នាក់ងារសេដ្ឋកិច្ចដែលត្រូវការហិរញ្ញវត្ថុសំរាប់ដំណើរការសកម្មភាព ។ សំរាប់សេវានេះ ធនាគារគិតកំរៃពីអ្នកខ្ចី ។កំរៃនេះសំរាប់ដោះស្រាយ ១) ចំណាយរកមូលនិធិពីអ្នកមានប្រាក់លើស, ២) ចំណាយប្រតិបត្តិការពាក់ព័ន្ធនឹងការផ្ដល់កំចី, ៣) ភាគរយមួយចំនែកសំរាប់ទូទាត់ការខាតបង់ក្នុងករណីអ្នកខ្ចីមិនព្រមសង ៤) និងប្រាក់ចំណេញដែលធនាគារត្រូវទទួលបានលើការហ៊ានប្រថុយផ្ដល់ឥណទាន ។ ធនាគារទាក់ទាញប្រាក់បញ្ញើពីអ្នកមានប្រាក់លើស ដោយទទួលសងប្រាក់បញ្ញើវិញនៅពេលមានសំណើ ដើម្បីឱ្យអ្នកផ្ញើប្រាក់ជឿជាក់ថា អាចដកប្រាក់របស់ខ្លួនបានភ្លាមជានិច្ច ។ ធនាគារត្រូវគ្រប់គ្រងតារាងតុល្យការរបស់ខ្លួន ដើម្បីមានប្រាក់ដោះស្រាយនៅពេលមានសំណើ ។ បើធនាគារមិនអាចប្រគល់ប្រាក់ទៅឱ្យអ្នកផ្ញើតាមសំណើបានទេ ប្រភពទុនរបស់ធនាគារ នឹងរីងស្ងួត ហើយធនាគារនឹងត្រូវបិទទ្វារ ។

បញ្ហាគន្លឹះមួយនៃការផ្ដល់ឥណទានគឺ អ្នកខ្ចីមួយចំនួនអាចមិនបង់ការប្រាក់ រឺមិនសងកំចី ស្របតាមកាតព្វកិច្ចរបស់ខ្លួនទេ ។ ទង្វើបែបនេះ នាំឱ្យធនាគារមានការខាតបង់លើការផ្ដល់ឥណទានដែលត្រូវរ៉ាប់រងដោយទុនផ្ទាល់របស់ធនាគារ ដូចជា ចំណូល រឺមូលធន

តារាង ២. អនុសាសន៍ក្នុងការសិក្សា MPDF

| លេខ | អនុសាសន៍ | ប្រភេទ |
|---|---|---|
| ៤.១ | តុលាការពាណិជ្ជកម្ម | ច្បាប់ |
| ៤.២ | ធ្វើវិសោធនកម្មច្បាប់ការពារភាពឯកជន | ច្បាប់ |
| ៤.៣ | ការតំរូវខាងសាច់ប្រាក់ | រដ្ឋបាល |
| ៤.៤ | ការចុះបញ្ជីទ្រព្យសម្បត្តិ | រដ្ឋបាល |
| ៤.៥ | ការបណ្ដុះបណ្ដាលពីហានិភ័យ | ធនាគារ |
| ៤.៦ | សេវាផ្ដល់ការប្រឹក្សាមតិ | ទីផ្សារ |
| ៤.៧ | ស្ថាប័នឥណទានមានជំនាញឯកទេស | ទីផ្សារ |
| ៤.៨ | ពន្ធកាត់ទុក | រដ្ឋបាល |

របស់ធនាគារ (គឺមិនមែនជាប្រាក់របស់ម្ចាស់បញ្ញើទេ) ។ ដើម្បីទប់ទល់នឹងទង្វើមិនល្អរបស់អ្នកខ្ចី ធនាគារបានអភិវឌ្ឍជំនាញឱ្យខ្ពស់ក្នុង "ការវាយតំលៃហានិភ័យ" ពីព្រោះ តាមរយៈបទពិសោធន៍ និងការវិភាគលើអតិថិជន ធនាគារដឹងថាអតិថិជនណាប្រហែលបំពេញកាតព្វកិច្ចបាន ហើយអតិថិជនណាអាចមានបញ្ហា ។ ផ្សារភ្ជាប់នឹងវិធីសាស្ត្រនេះ គឺការយកកំរៃខុសៗគ្នា ទៅតាមហានិភ័យៈ អតិថិជនណា ដែលត្រូវបានវាយតំលៃថាមានហានិភ័យមិនសងប្រាក់កំរិតខ្ពស់ ធនាគារគួរយកការប្រាក់ខ្ពស់ ដើម្បីប៉ះប៉ូវឱ្យធនាគារដែលត្រូវប្រឈមខ្លាំងនឹងការបាត់បង់ប្រាក់កំចី ។ មួយភាគធំនៃអត្រាការប្រាក់ខ្ពស់នេះ ត្រូវដាក់ក្នុងទុនបំរុងសំរាប់ការខាតបង់កំចី ដើម្បីរ៉ាប់រងការខាតបង់នានាដែលកើតចេញពីការផ្ដល់ឥណទាន ។

ចំនុចគន្លឹះនៅក្នុងការវាយតំលៃហានិភ័យគឺ "ស្គាល់អតិថិជន" ។ ធនាគារ រឺអន្តរការីហិរញ្ញវត្ថុណា ដែលចំណាយពេល និងកំលាំងស្វែងយល់ពីអតិថិជន និងពីអាជីវកម្មរបស់អតិថិជន នឹងមានការងាយស្រួលវាយតំលៃ ពីហានិភ័យទាក់ទិននឹងការផ្ដល់ឥណទានទៅឱ្យអតិថិជនជាក់លាក់ណាមួយ ។ "ស្គាល់អតិថិជន" គឺមិនមែនត្រឹមតែដឹងពីស្ថានភាពហិរញ្ញវត្ថុដ៏សំខាន់របស់អតិថិជននោះទេ ប៉ុន្តែវាពាក់ព័ន្ធផងដែរ នឹងការបង្កើនទំនាក់ទំនងជាមួយអតិថិជន ដើម្បីអោយធនាគារអាចដឹងពីដំណើរការអាជីវកម្មរបស់ពួកគេ ។ ដើម្បីយល់ដឹងពីអតិថិជន គេត្រូវចំនាយពេលច្រើន ប៉ុន្តែវាជាលក្ខខណ្ឌចាំបាច់ សំរាប់ឱ្យការផ្ដល់ឥណទានទទួលជោគជ័យ ពីព្រោះទំនាក់ទំនងធនាគារដែលមានជោគជ័យល្អ គឺជាទំនាក់ទំនងបន្តជាប់ក្នុងរយៈពេលវែង ដែលនឹងផ្ដល់ផលប្រយោជន៍ដល់ភាគីទាំងសងខាង ។

ការសិក្សាបានបង្ហាញលទ្ធផលមួយទៀតថា (§3.9, p. 30) អ្នកខ្ចីចូលចិត្តទាក់ទងនឹងទីផ្សារកំចីក្រៅផ្លូវការ ពីព្រោះ វាមានប្រសិទ្ធភាពជាង ។ តាមមើលឃើញ ទីផ្សារក្រៅផ្លូវការហាក់ដូចអាចប្រកួតប្រជែងជាមួយធនាគារបានក្នុងការយកថ្លៃ ។ ចំនុចនេះបង្ហាញថា ទីផ្សារក្រៅផ្លូវការស្គាល់អតិថិជនច្បាស់ជាងធនាគារ ហេតុនេះទើបអតិថិជនចូលចិត្តទីផ្សារក្រៅផ្លូវការ ។ ទីផ្សារក្រៅផ្លូវការ គឺជាទ្រង់ទ្រាយមួយនៃការងារឈ្នួញកណ្ដាលខាងហិរញ្ញវត្ថុដែរ ហើយក៏មានធ្វើការវាយតំលៃដូចគ្នាពីហានិភ័យលើអ្នកខ្ចី ។

ទីផ្សារក្រៅផ្លូវការ ត្រូវបានរំពឹងថា ធ្វើប្រតិបត្តិការជាមួយអតិថិជន ដែលមានហានិភ័យខ្ពស់ជាងអតិថិជនរបស់ធនាគារ ពីព្រោះ តាមធម្មតាទីផ្សារនេះមិនទាមទារការដាក់ធានានូវទ្រព្យសម្បត្តិរបស់អ្នកខ្ចីទេ ។ ម្យ៉ាងទៀត ការដែលទីផ្សារក្រៅផ្លូវការអាចប្រកួតប្រជែងថ្លៃជាមួយធនាគារបាន បង្ហាញថា ធនាគារមិនទាន់បានប្រើឧត្តមភាពប្រៀបធៀបរបស់ខ្លួន ដើម្បីប្រកួតប្រជែងជាមួយទីផ្សារនេះទេ (ឧទាហរណ៍ ធនាគារមិនទាន់ខំស្វែងយល់ពីអតិថិជន) ដូច្នេះ មិនគួរឱ្យភ្ញាក់ផ្អើលទេ ដែលទីផ្សារក្រៅផ្លូវការមានជោគជ័យច្រើនជាងក្នុងការទាក់ទាញអតិថិជន ។

ពុំមែនតែធនាគារនៅកម្ពុជាទេ ដែលត្រូវដំណើរការនៅក្នុងលក្ខខណ្ឌខាងស្ថាប័នមិនអំណោយផល ទីផ្សារធនាគារឯទៀតទាំងក្នុងអតីតកាល និងបច្ចុប្បន្នកាល សុទ្ធតែធ្លាប់ជួបឧបសគ្គនេះដូចគ្នា ។ ប៉ុន្តែកន្លងមក ឧបសគ្គបែបនេះ មិនបានរារាំងដល់ការបង្កើតទីផ្សារឥណទានធនាគារដ៏មានជោគជ័យ និងរស់រវើកនោះទេ ។ ធនាគារនៅក្នុងទីផ្សារទាំងនេះ បានដំណើរការនៅក្នុងរង្វង់ឧបសគ្គដែលខ្លួនត្រូវជួបហើយផ្ដោតថាមពលលើការកែលំអជំនាញវាយតំលៃហានិភ័យ តាមរយៈការដឹងស្គាល់ពីអតិថិជនរបស់ខ្លួន ។

## សេចក្ដីសន្និដ្ឋាន

បញ្ហាគន្លឹះនៃការផ្ដល់ឥណទានធនាគារនៅកម្ពុជា មិនមែនជាលក្ខខណ្ឌខាងស្ថាប័នដែលធនាគារត្រូវធ្វើប្រតិបត្តិការនោះទេ តែវាជាបែបបទដែលធនាគារឈោងទៅចាប់យកទីផ្សារឥណទាន ។ ធនាគារត្រូវផ្លាស់ប្ដូរវិធីសាស្ត្រទាំងស្រុងក្នុងការផ្ដល់ឥណទានដោយត្រូវៈ

១. ចំណាយធនធានចាំបាច់ដើម្បីយល់ដឹងពីអតិថិជន

២. យកចំណេះដឹងនេះទៅវាយតំលៃហានិភ័យដែលពាក់ព័ន្ធ

៣. កំនត់អត្រាកំរៃលើឥណទានទៅតាមហានិភ័យដែលពាក់ព័ន្ធ ។

ចំនុចទាំងនេះ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារ ។ ការផ្លាស់ប្ដូរឯទៀតដែលលើកឡើងដោយការសិក្សា MPDF ជួយឱ្យធនាគារមានភាពងាយស្រួលនឹងផ្ដល់ឥណទានទៅឱ្យ SMEs ប៉ុន្តែការផ្លាស់ប្ដូរទាំងនេះមិនគ្រប់គ្រាន់ទេ លើកលែងតែធនាគារខ្លួនឯងចំនាយកំលាំងស្វែងរកឱកាសផ្ដល់ឥណទានដែលហុចផលចំនេញ ។

អង្កេតក្រៅផ្លូវការនាពេលថ្មីៗដោយ វិបសអ ដូចបានលើកឡើងនៅខាងលើ បានបង្ហាញខ្លះៗពីការផ្លាស់ប្ដូរឥរិយាបថជាវិជ្ជមានរបស់ធនាគារ ចំពោះការផ្ដល់ឥណទាន ។ ការផ្លាស់ប្ដូរនេះត្រូវការពេលវេលាមួយចំនួន មុននឹងលេចចេញច្បាស់នៅក្នុងទីផ្សារធនាគារ ប៉ុន្តែមានការណែនាំថា ធនាគារគួរចាប់ផ្ដើមយកចិត្តទុកដាក់លើការផ្ដល់កំចី ដោយចាត់ទុកវាជាសកម្មភាពចំបងមួយសំរាប់ការរកចំណូល ។

## កំណត់សំគាល់

១. MPDF (Mekong Project Development Facility), Private Sector Discussions, Number 14, Financing SMEs in Cambodia: Why do Banks Find it so Difficult?, May 2003

២. "ហេតុអ្វីបានជាធនាគារកម្ពុជាស្ទាក់ស្ទើរក្នុងការផ្ដល់ឥណទាន", ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា, ឆ្នាំទី៧ លេខ៣ (ភ្នំពេញៈ វិបសអ, កក្កដា-កញ្ញា ២០០៣), ទំព័រ ១២-១៣ ។

**ឯកសារយោងសូមអានអត្ថបទជាភាសាអង់គ្លេស**

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

## កំណើនសេដ្ឋកិច្ចពិភពលោក

កំឡុងត្រីមាសទី៤ ២០០៥ សេដ្ឋកិច្ចពិភពលោក មានដំណើរការយឺតៗ ។ ផសស ពិតរបស់ US មានកំរិត ១,១% ខ្ពស់ជាងនៅត្រីមាសទី៤ ២០០៤ និងធ្លាក់ចុះពី ៤,១% នៅត្រីមាសទី៣ ២០០៥ ។ ការធ្លាក់ចុះកំណើន ផសស ពិតនេះ បណ្ដាលជាសំខាន់មកពីការធ្លាក់ចុះចំណាយប្រើប្រាស់ផ្ទាល់ខ្លួន កំណើនការនាំចេញ ការថយចុះចំនាយរដ្ឋាភិបាលសហព័ន្ធការថយកំណើនផលិតកម្មគ្រឿងបរិក្ខានិងសូហ្វវែរ និងវិនិយោគលើសំណង់ផ្ទះសំបែង ។

ផសស ពិត នៅតំបន់អឺរ៉ូ នៅត្រីមាសទី៤ កើនបាន ១,៨% លើមូលដ្ឋានប្រចាំឆ្នាំនិងបាន០,៣% ធៀបនឹងត្រីមាសមុន ។ធៀបនឹងមួយឆ្នាំមុនចំនាយប្រើប្រាស់ចុងក្រោយរបស់គ្រួសារកើនបាន ១,១% ចំណាយប្រើប្រាស់របស់រដ្ឋាភិបាលកើន ១,៩% ការវិនិយោគ ២,៧% ការនាំចេញនិងនាំចូល ៤,៩%និង៥,២% រៀងគ្នា ។

ផសស ពិតរបស់ជប៉ុនកើនបាន ៤,៥% ក្នុងរយៈមួយឆ្នាំដល់ត្រីមាសទី៤ ២០០៥ រឺជាអត្រាខ្ពស់ជាងគេ ក្នុង៥ឆ្នាំកន្លងមក និងកើនបាន ១,៣% ធៀបនឹងត្រីមាសមុន ។ ចិននៅតែមានកំណើនសេដ្ឋកិច្ចខ្ពស់នៅត្រីមាសទី៤ ២០០៥ ដោយមានកំណើន ផសស ពិតប្រចាំឆ្នាំ ៩,៩% រឺ ០,៥% ខ្ពស់ជាងនៅត្រីមាសមុន ។ ក្នុងនេះវិស័យឧស្សាហកម្ម មានកំណើនខ្ពស់បំផុតក្នុងអត្រា ១១,៤% រីឯវិស័យសេវាកម្ម និងវិស័យកសិកម្ម-យករ៉ែ មានកំណើន ៩,៦% និង ៥,២% រៀងគ្នា ។

នៅត្រីមាសទី៤ ២០០៥ ផសស ពិតប្រចាំឆ្នាំរបស់កូរ៉េខាងត្បូង គឺ ៥,២% ធៀបនឹង ៤,៤% នៅត្រីមាសទី៣ ។ វិស័យឧស្សាហកម្មផលិត កើនបាន ១០% នាំមុខគេដោយផលិតផលអគ្គិសនី និងអេឡិចត្រូនិក (រួមមានទាំងផលិតផលពាក់កណ្ដាលចំលង វិទ្យុ ទូរទស្សន៍ និងសំភារៈទូរគមនាគមន៍) ។ ធាតុចេញនៃវិស័យសេវាកម្ម កើនឡើងបាន ៣,៩% ដោយសារកំណើនពាណិជ្ជកម្មលក់ដុំនិងលក់រាយ ការដឹកជញ្ជូន និងស្តុកទំនិញ ។

កំណើន ផសស ពិតក្នុងរយៈមួយឆ្នាំរបស់ម៉ាឡេស៊ីកើនបាន ៥,២% នៅត្រីមាសទី៤ ២០០៥ ធៀបនឹង ៥,៣% នៅត្រីមាសមុន ។ ឧស្សាហកម្មផលិតមានកំណើន ៧,៣% រីឯនៅផ្នែកចំណាយកំណើននាំមុខគេដោយការចំណាយរបស់រដ្ឋាភិបាល ដែលកើនបាន ១២,៨% ។ សេដ្ឋកិច្ចសិង្ហបុរីនៅត្រីមាសទី៤ បន្តកើនឡើងយ៉ាងខ្លាំងក្នុងអត្រា ៧,៧% ធៀបនឹងមួយឆ្នាំមុន ។ ឧស្សាហកម្មផលិតកើនបាន ១១,៥% ជាសំខាន់ដោយសារកំណើនយ៉ាងខ្ពស់លើជីវឱសថ វិស្វកម្មដឹកជញ្ជូន និងផលិតផលអេឡិចត្រូនិច រីឯវិស័យសេវាកម្មកើនបាន ៧% ។ កំណើន ផសស ពិតប្រចាំឆ្នាំថៃ នៅត្រីមាសទី៤ គឺ ៤,៧% ដោយធ្លាក់ចុះ ធៀបនឹងអត្រា ៥,៣% នៅត្រីមាសមុន ។ ផលិតផលកសិកម្ម ធ្លាក់ចុះអស់ ៣,៦% រីឯឧស្សាហកម្មផលិតនិងសេវាកម្មកើនបាន ១,៨% និង ០,៧% រៀងគ្នា ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់នៅទីផ្សារអន្តរជាតិ

នៅត្រីមាសទី៤ ២០០៥ ថ្លៃទំនិញប្រើប្រាស់នៅ US មានកំរិត ៣,៧% ខ្ពស់ជាងកាលពីមួយឆ្នាំមុន ។ ខ្យល់ព្យុះ អស្ថិរភាពនៅតំបន់កណ្ដាលភាគខាងកើត និងកំណើនតំរូវការរបស់ចិន បានជំរុញឱ្យថ្លៃថាមពលឡើងខ្ពស់ ដែលនាំមកនូវកំណើនថ្លៃទំនិញប្រើប្រាស់ជាទូទៅ ។ នៅតំបន់អឺរ៉ូ ក្នុងរយៈមួយឆ្នាំ ថ្លៃទំនិញ កើនបាន ២,៤% ខ្ពស់ជាងការកំណត់ ២% របស់ធនាគារកណ្ដាលអឺរ៉ុប ដែលបណ្ដាលមកពីកំណើនថ្លៃថាមពល និងថ្លៃម្ហូបអាហារមិនទាន់កែច្នៃ ។ នៅជប៉ុន ថ្លៃទំនិញប្រើប្រាស់ធ្លាក់ចុះអស់ ០,៥% ក្នុងរយៈមួយឆ្នាំដល់ចុងត្រីមាសទី៤ និងធ្លាក់ចុះថែមទៀត ធៀបនឹងអត្រា ០,៣% នៅត្រីមាសទី៣ ។ មូលហេតុសំខាន់នៃនិន្នាការធ្លាក់ចុះនេះ ដោយសារការធ្លាក់ចុះថ្លៃម្ហូបអាហារ ថ្លៃសេវាអប់រំទាប និងការធ្លាក់ចុះនៃចំណាយលំហែកំសាន្ត ។ កំណើនថ្លៃទំនិញប្រើប្រាស់ប្រចាំឆ្នាំនៅចិនមានកំរិត ១,៤% ខ្ពស់ជាងអត្រា ១,៣% នៅត្រីមាសមុន ។

នៅត្រីមាសទី៤ ដុល្លារUS កើនតំលៃទល់នឹងរូបិយវត្ថុសំខាន់ៗផ្សេងទៀត ។ ទល់នឹងប្រាក់អឺរ៉ូ ដុល្លារUS ប្តូរបាន ០,៨៤អឺរ៉ូ/ដុល្លារUS ខ្ពស់ជាង ០,៨១អឺរ៉ូ/ដុល្លារUS នៅត្រីមាសទី៣ ។ វាប្តូរជាមួយប្រាក់ជប៉ុនបាន ១១៧,២យ៉េន/ដុល្លារUS កើនពី ១១១,២យ៉េន/ដុល្លារUS នៅត្រីមាសមុន ។ គំលាតនៃអត្រាការប្រាក់កាន់តែធំ រវាងសហរដ្ឋអាមេរិច និងប្រទេសសេដ្ឋកិច្ចសំខាន់ៗ ហាក់ជួយទ្រទ្រង់ដល់ដុល្លារUS ។ ការទ្រទ្រង់បន្ថែមទៀត បានមកពីព័ត៌មានថា តំរូវការបរទេសចំពោះសន្លឹកហ៊ុនUS នៅតែមានកំរិតខ្ពស់ ដូចដែលបានឃើញច្បាស់ នូវកំណើននៃលំហូរវិនិយោគចូលទៅ US ។

## ថ្លៃផលិតផលនៅលើទីផ្សារពិភពលោក

នៅត្រីមាសទី៤ ២០០៥ ថ្លៃផលិតផលជ្រើសរើសមួយចំនួនក្នុងទីផ្សារអន្តរជាតិ មិនមានការប្រែប្រួលធំដុំទេ ។ ថ្លៃអង្ករ ពោត និងប្រេងឆា កើនឡើង រីឯថ្លៃសណ្ដែកសៀង ប្រេងឆៅ និងសាំង ធ្លាក់ចុះ ។ ថ្លៃអង្ករ ស Thai 100%B លេខ២ នៅទីផ្សារបាងកក លក់បាន ២៨៦ដុល្លារ/តោន ខ្ពស់ជាង ២៨២ដុល្លារ/តោន នៅត្រីមាស ទី៣ ។ ប្រេងឆា លក់បាន ៤៣១,៦៦ដុល្លារ/តោន រឺ កើនឡើង ៤,០% ធៀបនឹងត្រីមាសមុន ។ ថ្លៃពោតនៅថៃ ប្រហែល ៩៩,៩០ដុល្លារ/តោន ។សណ្ដែកសៀងលក់បាន ២៣២ដុល្លារ/តោន ទាបជាង ២៣៦,៣៥ដុល្លារ/តោន នៅត្រីមាសទី៣ ។ ថ្លៃប្រេងឆៅ និងសាំង ធ្លាក់ចុះអស់ ៧,៤% និង ១៩% រៀងគ្នា ធៀបនឹងត្រីមាសទី៣ ។ ប្រេងឆៅលក់បាន ៥២,៩៩ដុល្លារ/ធុង រីឯសាំងលក់បាន ៤២,២៩សេន/លីត្រ ។

*រៀបរៀងដោយ ហ៊ិង វុត្ថា និង គីម រុនស៊ីណារិទ្ធិ*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

តារាង១. កំនើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០០-២០០៥ ( កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2000 | 2001 | 2002 | 2003 | 2004 | 2005 | | | | 2004 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q4 | Q1 | Q2 | Q3 | Q4 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 7.3 | 6.7 | 4.8 | 7.0 | - | - | - | - | - | 7.7 |
| ឥណ្ឌូនេស៊ី | 4.4 | 3.8 | 3.8 | 4.9 | 6.6 | 6.4 | 5.5 | 5.3 | 4.9 | 5.1 |
| ម៉ាឡេស៊ី | 8.7 | 0.5 | 5.6 | 5.4 | 5.6 | 5.7 | 4.4 | 5.3 | 5.2 | 7.0 |
| សិង្ហបុរី | 9.5 | -2.3 | 2.6 | 1.4 | 6.5 | 2.5 | 5.4 | 7.0 | 7.7 | 8.5 |
| ថៃ | 4.4 | 1.9 | 6.1 | 6.9 | 5.0 | 3.3 | 4.6 | 5.3 | 4.7 | 6 |
| វៀតណាម | | 6.0 | 6.7 | 7.0 | - | - | - | - | - | 7.5 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 8.0 | 7.5 | 8.1 | 9.9 | 9.5 | 9.5 | 9.5 | 9.4 | 9.9 | 9.5 |
| ហុងកុង | 10.2 | 0.5 | 5.0 | 3.2 | 7.1 | 2.7 | 7.3 | 8.2 | - | 8.3 |
| កូរ៉េខាងត្បូង | 9.1 | 3.0 | 6.1 | 3.0 | 3.3 | 6.0 | 3.3 | 4.4 | 5.2 | 4.7 |
| តៃវ៉ាន់ | 5.8 | -2.2 | 4.2 | 3.1 | 3.3 | 2.7 | - | - | 6.0 | 5.7 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ុប-១២ | 3.5 | 1.4 | 0.7 | 0.5 | 1.6 | 1.3 | 1.2 | 1.5 | 1.8 | 1.8 |
| ជប៉ុន | 2.8 | 0.4 | 0.4 | 2.6 | 0.8 | 1.3 | 1.4 | 2.9 | 4.5 | 3.4 |
| សហរដ្ឋអាមេរិក | 5.0 | 1.2 | 2.4 | 3.1 | 3.8 | 3.5 | 3.3 | 4.1 | 1.1 | 4.4 |

Sources: Economist, countries' national statistics offices and central banks and ADB's Asia Regional Information Centre

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០០-២០០៥ ( កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2000 | 2001 | 2002 | 2003 | 2004 | 2005 | | | | 2004 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q4 | Q1 | Q2 | Q3 | Q4 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | -0.8 | -0.6 | 3.2 | 1.2 | 6.1 | 5.9 | 6.9 | 6.0 | 7.3 | 4.0 |
| ឥណ្ឌូនេស៊ី | 3.6 | 11.5 | 13.2 | 8.3 | 8.6 | 10.7 | 10.8 | 12 | 17.3 | 8.3 |
| ម៉ាឡេស៊ី | 1.5 | 1.4 | 1.8 | 1.1 | 2.4 | 2.5 | 3.0 | 3.4 | 3.4 | 1.6 |
| សិង្ហបុរី | 1.4 | 1.0 | -0.4 | 0.5 | 1.7 | 0.4 | 0.1 | 0.5 | 1.1 | 1.7 |
| ថៃ | 1.5 | 1.7 | 0.6 | 1.8 | 3.1 | 2.8 | 5.3 | 5.6 | 6.0 | 2.7 |
| វៀតណាម | -1.7 | -0.4 | 3.8 | 3.2 | 10.7 | 10 | 9.2 | - | - | 8.3 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 0.3 | 0.9 | -0.7 | 1.2 | 3.2 | 2.8 | 1.7 | 1.3 | 1.4 | 3.9 |
| ហុងកុង | -3.6 | -1.3 | -3.0 | -2.6 | 0.2 | 0.4 | 0.8 | 1.4 | 1.8 | -0.4 |
| កូរ៉េខាងត្បូង | 2.3 | 4.4 | 2.7 | 3.5 | 3.4 | 3.2 | 3.2 | 2.4 | 2.5 | 3.5 |
| តៃវ៉ាន់ | 1.3 | -0.01 | -0.2 | -0.3 | 1.9 | 1.6 | 2.1 | - | 2.4 | 1.6 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ុប-១២ | 2.3 | 2.6 | 2.2 | 2.1 | 2.3 | 2.1 | 2.1 | 2.3 | 2.4 | 2.2 |
| ជប៉ុន | -0.7 | -0.6 | -0.9 | -0.3 | 0.5 | -0.2 | -0.1 | -0.3 | -0.5 | Nil |
| សហរដ្ឋអាមេរិក | 3.3 | 2.8 | 1.6 | 2.3 | 3.3 | 3.0 | 2.9 | 3.8 | 3.7 | 2.7 |

Sources: International Monetary Fund, Economist and National Institute of Statistics

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០០-២០០៥ ( មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2000 | 2001 | 2002 | 2003 | 2004 | 2005 | | | | 2004 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q4 | Q1 | Q2 | Q3 | Q4 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា ( រៀល) | 3,840.8 | 3,916.3 | 3,912.1 | 3,973 | 4,034.7 | 4,027.0 | 4,054.3 | 4134.3 | 4160.0 | 4,016.3 |
| ឥណ្ឌូនេស៊ី ( រូពីយ៉ា) | 8,421 | 10,261 | 9,311 | 8,577 | 9,128 | 9,274 | 9,550 | 9,994 | - | 8,938 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.77 | 3.78 | 3.80 |
| សិង្ហបុរី ( ដុល្លារសិង្ហបុរី) | 1.72 | 1.79 | 1.79 | 1.74 | 1.65 | 1.63 | 1.66 | 1.68 | 1.69 | 1.69 |
| ថៃ ( បាត) | 40.1 | 44.4 | 42.9 | 41.5 | 40.3 | 38.6 | 40.1 | 41.3 | 41.02 | 40.2 |
| វៀតណាម ( ដុង) | 14,168 | 14,725 | 15,280 | 15,510 | - | 15,809 | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន ( យ៉ុន) | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.14 | 8.08 | 8.28 |
| ហុងកុង ( ដុល្លារហុងកុង) | 7.80 | 7.80 | 7.80 | 7.78 | 7.78 | 7.80 | 7.79 | 7.77 | 7.75 | 7.79 |
| កូរ៉េខាងត្បូង (វ៉ុន) | 1,131 | 1,291 | 1,251 | 1,192 | 1,093 | 1,022 | 1,008 | 1,029 | 1,036 | 1,145 |
| តៃវ៉ាន់ ដុល្លារតៃវ៉ាន់ (NT$) | 31.2 | 33.8 | 34.5 | 34.4 | 32.9 | 31.5 | 31.4 | 32.3 | 33.4 | 33.6 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ុប-១២ ( អឺរ៉ូ) | 1.09 | 1.12 | 1.06 | 0.89 | 0.77 | 0.76 | 0.79 | 0.81 | 0.84 | 0.80 |
| ជប៉ុន ( យ៉េន) | 107.8 | 121.5 | 125.4 | 115.9 | 105.9 | 104.7 | 107.4 | 111.2 | 117.2 | 108.2 |

Source: The International Monetary Fund and The Economist and National Bank of Cambodia

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០០-២០០៥ ( មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2000 | 2001 | 2002 | 2003 | 2004 | 2005 | | | | 2004 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q4 | Q1 | Q2 | Q3 | Q4 | |
| ពោត (US No. 2) - US ($/តោន) | 88.4 | 89.5 | 99.21 | 105.2 | 94.4 | 97.0 | 96.5 | 99.9 | 99.93 | 122.0 |
| ប្រេងឆា- អឺរ៉ុបពាយព្យ ($/តោន) | 310.2 | 285.7 | 390.2 | 443.25 | 429.0 | 413.3 | 421.7 | 415 | 431.66 | 471.3 |
| កៅស៊ូ - ម៉ាឡេស៊ី ($/តោន) | 720.8 | 602.0 | 768.3 | 1050 | 1238.2 | - | - | - | - | 1252.2 |
| អង្ករ (Thai 100%B) - បាងកក ($/តោន) | 206.7 | 177.3 | 196.9 | 200.9 | 264.9 | 295.6 | 295.7 | 282.0 | 286.0 | 244.4 |
| សណ្ដែកសៀង (US No. 1) - US ($/តោន) | 193.0 | 180.7 | 201.3 | 241.3 | 216.5 | 229.9 | 290.7 | 236.35 | 232.0 | 288.9 |
| ប្រេងឆៅ-ឌូបៃ ($/ធុង) | 26.1 | 22.8 | 23.9 | 26.8 | 35.5 | 42.6 | 47.7 | 57.27 | 52.99 | 33.5 |
| សាំង - US Gulfcoast ( សេន/លីត្រ) | 21.1 | 19.5 | 19.1 | 23.0 | 31.8 | 34.4 | 39.7 | 52.37 | 42.29 | 30.9 |

Source: Food and Agriculture Organization (FAO) and US Energy Information Administration

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសចុងក្រោយ ឆ្នាំ២០០៥ សកម្មភាពសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជាមានដំណើរការយឺតបន្តិច ធៀបនឹងត្រីមាសមុន ។ វិនិយោគឯកជន ការសាងសង់ និងពាណិជ្ជកម្មក្រៅប្រទេស បានធ្លាក់ចុះ ទោះបីជាមានកំណើនភ្ញៀវទេសចរក្តី ។

បន្ទាប់ពីមានការកើនឡើង ដោយសារគំរោងវិនិយោគធំៗបានអនុម័តនៅត្រីមាសទី៣ តំលៃនៃការវិនិយោគឯកជនលើទ្រព្យសកម្មជាប់លាប់បានចុះបញ្ជីនៅត្រីមាសទី៤ ធ្លាក់ចុះអស់ ៧១% ដល់ ១១៩លានដុល្លារ ។ វិនិយោគឯកជនក្នុងវិស័យសំខាន់ៗទាំង៣ បានធ្លាក់ចុះទាំងអស់នៅកំឡុងពេលនោះ ដែលនាំមុខគេដោយវិស័យឧស្សាហកម្ម ។វិនិយោគឧស្សាហកម្មលើទ្រព្យសកម្មជាប់លាប់បានចុះបញ្ជី ធ្លាក់ចុះអស់ ៧៧% ដល់ ៨២លានដុល្លារ រីឯវិនិយោគវិស័យសេវាកម្ម ធ្លាក់អស់ ៣៦% (ដល់ ២៨លានដុល្លារ) និងវិនិយោគវិស័យកសិកម្មធ្លាក់អស់១៣%(ដល់៩លានដុល្លារ) ។ ប៉ុន្តែ តំលៃសរុបនៃវិនិយោគឯកជនលើទ្រព្យសកម្មជាប់លាប់ បានអនុម័តនៅឆ្នាំ២០០៥ (រួមទាំងគំរោងពង្រីកបន្ថែមផ្សេងទៀត) កើនដល់ ១០៩៥លានដុល្លារ រឺប្រហែល ៤ដងនៃកំរិតនៅឆ្នាំ ២០០៤ ។ រឿងនេះបណ្តាលមកពីកំណើនវិនិយោគក្នុងវិស័យឧស្សាហកម្ម បន្ទាប់មកវិស័យកសិកម្ម និងសេវាកម្ម ។អនុវិស័យឧស្សាហកម្មចំនួន៤បានទាក់ទាញគំរោងវិនិយោគទ្រង់ទ្រាយធំនៅឆ្នាំ២០០៥: ការចំរាញ់ប្រេងកាត (២០១លានដុល្លារ) ផលិតកម្មស៊ីម៉ង់ត៍ (១៨១លានដុល្លារ) ការយករ៉ែ (១៧៩លានដុល្លារ) និងការកាត់ដេរសំលៀកបំពាក់ (១៥២លានដុល្លារ) ។

សកម្មភាពសាងសង់ ដែលតំណាងដោយតំលៃគំរោងសាងសង់បានអនុម័តនៅភ្នំពេញ ធ្លាក់ចុះតាំងពីត្រីមាសទី១ ២០០៥ ។ នៅត្រីមាសទី៤ ២០០៥ តំលៃគំរោងអនុម័តគឺ ៧២លានដុល្លារ រឺ ៦,១% ទាបជាងត្រីមាសមុន ។ ការធ្លាក់ចុះនេះ បណ្តាលមកពីការធ្លាក់ចុះ ៧២% លើសកម្មភាពសាងសង់ភូមិគ្រឹះនិងផ្ទះ ប៉ុន្តែត្រូវប៉ះប៉ូវដោយកំនើន ៩.២% លើការសាងសង់ផ្ទះល្វែង និង ៣៣% លើការសាងសង់សំណង់ផ្សេងទៀត ។ ទោះជាយ៉ាងនេះក្តី សកម្មភាពសាងសង់នៅភ្នំពេញ បានកើនឡើងបន្តរហូតនៅបីឆ្នាំចុងក្រោយ ។ នៅឆ្នាំ២០០៥ គំរោងអនុម័តកើនបាន ៣៦% ដល់ ៣៥៩លានដុល្លារ ធៀបនឹង ២៦៤លានដុល្លារនៅឆ្នាំ២០០៤ ។ ក្នុងនេះការសាងសង់ផ្ទះល្វែង មានទំហំធំជាងគេបំផុត (២០៤លានដុល្លារ នៅឆ្នាំ២០០៥) រឺ កើន ២២% ។ តំលៃនៃគំរោង សាងសង់ភូមិគ្រឹះនិងផ្ទះ និងសំណង់ផ្សេងទៀតបានអនុម័ត ក៏កើនឡើងផងដែរនៅឆ្នាំ ២០០៤-០៥ ដោយកើនបាន ៥០% ដល់ ៤៦លានដុល្លារ និង ៦៦% ដល់ ១០៩លានដុល្លាររៀងគ្នា ។

ការធ្លាក់ចុះនៃការនាំចេញសរុប (ជាសំខាន់ដោយសារការធ្លាក់ចុះនៃការនាំចេញសំលៀកបំពាក់) រួមផ្សំនឹងកំណើនការនាំចូលសរុបធ្វើឱ្យពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជាមានឱនភាព ៤៦លានដុល្លារនៅត្រីមាសទី៤ ធៀបនឹងអតិរេក ៩៨លានដុល្លារ នៅត្រីមាសមុន ។ ជាទូទៅ ការនាំចេញសំលៀកបំពាក់កើនដល់កំពូលនៅ ត្រីមាសទី៣ និងធ្លាក់ចុះនៅត្រីមាសទី៤ ហើយស្របតាមលំនាំនេះ ការនាំចេញសរុបបានធ្លាក់ចុះអស់ ១២% ដល់ ៦៤៥លានដុល្លារ នៅត្រីមាសទី៤ ២០០៥ ។ នៅកំឡុងពេលដូចគ្នា ការនាំចូលសរុបកើន ៩,៣% ដល់ ៦៩១លានដុល្លារ បណ្តាលមកពីកំណើន ២២% លើការនាំចូលម្ហូបអាហារនិងភេសជ្ជៈ និងកំណើន ១១% លើការនាំចូលយានយន្ត ។

សំរាប់ឆ្នាំ ២០០៥ ឱនភាពពាណិជ្ជកម្មមាន ១៥៨លានដុល្លារ គឺ ៤,៥ដង ខ្ពស់ជាងនៅឆ្នាំ២០០៤ ដែលមានឱនភាពតែ ២៩លានដុល្លារ ។ នៅឆ្នាំ២០០៤-០៥ កំណើនការនាំចូល (១៨%) ខ្ពស់ជាងកំណើនការនាំចេញ (១២%) បណ្តាលឱ្យមានឱនភាពពាណិជ្ជកម្មកាន់តែខ្លាំង ។ ការនាំចូលកើនបណ្តាលមកពីកំណើនការនាំចូលសំភារៈសាងសង់ (៤១%) យានយន្ត (៣៣%) និងក្រណាត់ សំលៀកបំពាក់ប្រើហើយនិងថ្មី (១៧%) ។

ផ្ទុយទៅវិញ នៅត្រីមាសទី៤ ២០០៥ វិស័យទេសចរណ៍ (គិតជាចំនួនភ្ញៀវបរទេស) កើនឡើងបាន ២៥% ដល់ ៤១៦.០០០នាក់ ។ នៅឆ្នាំ២០០៥ ភ្ញៀវបរទេសមកកម្ពុជាសរុបមាន ១.៤១៣.៥៤៤នាក់ រឺ ៣៤% ខ្ពស់ជាងនៅឆ្នាំមុន ។ ភ្ញៀវមកតាមផ្លូវអាកាស កើនបាន ៣៧% ដល់ ៨៥៥.៨០០នាក់ ដែល ៥១% ជាភ្ញៀវមកតាមព្រលានយន្តហោះ អន្តរជាតិសៀមរាប (កើន ៤២%) ។ លើសពីនេះ ភ្ញៀវមកតាមផ្លូវគោក និងផ្លូវទឹក កើនបាន ៣០% ដល់ ៥៥៧.៦៩៤នាក់ ដែលឆ្លុះបញ្ចាំងពីកំណើនយ៉ាងច្រើននៃភ្ញៀវមកតាមផ្លូវគោក (៧៥%) ។

## ហិរញ្ញវត្ថុសាធារណៈ

ឱនភាពថវិការបស់រដ្ឋាភិបាល មានភាពធូរស្រាលនៅត្រីមាសចុងក្រោយឆ្នាំ២០០៥ ដោយមានចំនួន ១៩៥ពាន់លានរៀល ធៀបនឹង ៣២៨ពាន់លានរៀល នៅត្រីមាសមុន ។ ចំណូលរដ្ឋាភិបាលកើនបាន ៣៣% ដល់ ៨២៨ពាន់លានរៀល បណ្តាលមកពីកំណើន ២៧% លើចំណូលពន្ធ និងកំណើនយ៉ាងខ្ពស់លើចំណូលមូលធន ។ នៅត្រីមាសទី៤ ចំណាយសរុបកើន ៧% ដល់ ១០២២ពាន់លានរៀល ដែលឆ្លុះបញ្ចាំងពីកំណើន ១២% លើចំណាយចរន្ត ប៉ុន្តែមានការធ្លាក់ចុះ ០,៤% លើចំណាយមូលធន ។

នៅឆ្នាំ២០០៥ ចំណូលរដ្ឋាភិបាលសរុបកើនបាន ២៣% ដល់ ២៦២៥ពាន់លានរៀល ដោយសំរេចបាន ១១៤% នៃផែនការប្រចាំឆ្នាំ ។ ប៉ុន្តែចំណាយថវិកាសរុប ក៏មានការកើនឡើងដែរ បាន ១៥% ដល់ ៣៤៥៤ពាន់លានរៀល រឺ ១១១% នៃផែនការ ។ រឿងនេះ ធ្វើមានការថយចុះឱនភាពថវិកាមកត្រឹម ៨២៨ពាន់លានរៀលនៅឆ្នាំ២០០៥ ធៀបនឹង ៨៦៤ពាន់លានរៀលនៅឆ្នាំ២០០៤ ។

កំណើនចំណូលថវិកាសរុប បណ្តាលជាសំខាន់ពីកំណើន ១៧% លើចំណូលចរន្ត និងកំណើនយ៉ាងខ្ពស់ លើចំណូលមូលធន ។ កំណើននេះបណ្តាលមកពីកំណើនពន្ធប្រមូលបាន (២១%) ជាពិសេសពន្ធលើការនាំចូលយានយន្តដែលធ្វើឡើងនៅដើមឆ្នាំ២០០៥និងការលក់ទ្រព្យសម្បត្តិរដ្ឋនៅចុងឆ្នាំ ។ ចំណាយចរន្ត និងចំណាយមូលធន មានកំណើន ១៣% និង ១៨% រៀងគ្នា ។ ចំណាយចរន្តលើប្រាក់បៀវត្សរ៍កើនបាន ១១% ដោយសារវិធានការ កែទំរង់សេវាកម្មស៊ីវិល ហើយរដ្ឋាភិបាលមានបំណងបង្កើនប្រាក់បៀវត្សរ៍ ១៥% ដល់មន្ត្រីរាជការ និងកងទ័ពនៅឆ្នាំ២០០៥ ។

## អតិផរណា និងអត្រាប្តូរប្រាក់

នៅត្រីមាសចុងក្រោយឆ្នាំ ២០០៥ ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញ បន្តកើន

ឡើង ។ ថ្លៃទំនិញកើនបាន ៦,៦% ធៀបនឹងត្រីមាសទី៤ ២០០៤ និងកើន ៤,៦% ធៀបនឹងត្រីមាសមុន ។ ថ្លៃម្ហូបអាហារកើន ១១% ធៀបនឹងកំណើន ៦,០% នៅត្រីមាសទី៣ រីឯកំណើនថ្លៃដឹកជញ្ជូន និងទូរគមនាគមន៍ថយចុះមកត្រឹម ១០% ធៀបនឹង ១២% នៅត្រីមាសមុន ។

អត្រាប្តូរប្រាក់រវាងប្រាក់រៀលនិងដុល្លារUS គឺ៤១៥៤រៀល/ដុល្លារនៅត្រីមាសទី៤ ដោយធ្លាក់ថ្លៃអស់ ០,៥% ធៀបនឹងត្រីមាសទី៣ ។ ទល់នឹងប្រាក់បាតថៃ ប្រាក់រៀលក៏ធ្លាក់ថ្លៃអស់ ១,២% មកត្រឹម ១០១,៤រៀល/បាត ។ ដូចគ្នាដែរ ប្រាក់រៀលធ្លាក់ថ្លៃទល់នឹងប្រាក់ដុងវៀតណាម អស់ ០,៨% ដោយប្តូរបាន ២៦,១រៀល/១០០ដុង នៅត្រីមាសទី៤ ។

## ការវិវត្តន៍រូបិយវត្ថុ

នៅចុងត្រីមាសទី៤ ២០០៥ រូបិយវត្ថុទូទៅ(M2) បន្តកើនឡើងបាន ០,៦% ធៀបនឹងត្រីមាសមុន ដល់ ៥០២៥ពាន់លានរៀល ដែលនាំមុខគេដោយកំណើន ៣,២% នៃប្រាក់រៀលនៅក្រៅធនាគារ ។ រឿងនេះ បណ្តាលមកពីកំណើន ៣,៦% នៃក្រដាស់ប្រាក់រៀលចេញថ្មី ។

ទោះជាយ៉ាងណាក្តី កំណើនរូបិយវត្ថុធ្លាក់ចុះមកត្រឹម ១៦% នៅឆ្នាំ ២០០៥ ធៀបនឹងកំណើន ៣០% នៅឆ្នាំ ២០០៤ ។ មូលហេតុចំបងនៃការធ្លាក់ចុះនេះ គឺការថយកំណើននៃទ្រព្យសកម្មបរទេសសុទ្ធ (ថយកំណើនពី ១៩% មកត្រឹម ១៤%) និងឥណទានដល់វិស័យឯកជន (ថយកំណើនពី ៣៦% មកត្រឹម ៣២%) ។

## ស្ថានភាពក្រីក្រ និងប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពលករងាយរងគ្រោះ

អង្កេតទៀងទាត់ប្រចាំត្រីមាសរបស់ វបសអ លើពលករងាយរងគ្រោះ ធ្វើឡើងនៅកំឡុងពេលពីថ្ងៃទី១៥ ខែកុម្ភៈ ដល់ ថ្ងៃទី៣ ខែមីនា ២០០៦ បង្ហាញនូវការធ្លាក់ចុះប្រាក់ចំនូលប្រចាំថ្ងៃ របស់ក្រុមពលករងាយរងគ្រោះភាគច្រើន ដូចជា អ្នករត់ម៉ូតូឌុប កម្មករសំណង់មានជំនាញ កម្មករកាត់ដេរ អ្នកធាក់ស៊ីក្លូ កម្មករលីសែង អ្នករើសសំរាម និងអ្នកលក់បន្លែតូចតាច ធៀបនឹងកំឡុងពេលដូចគ្នាកាលពីឆ្នាំមុន ។ ក្នុងនេះ ប្រាក់ចំណូលរបស់អ្នករត់ម៉ូតូឌុប និងកម្មករសំណង់មានជំនាញ បានធ្លាក់ចុះច្រើនជាងគេ ។

ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នករត់ម៉ូតូឌុប ធ្លាក់ចុះ ២៤,៥% មកត្រឹម ៨៩០០រៀល ធៀបនឹង ១១.៨០០រៀលនៅកំឡុងពេលដូចគ្នាកាលពីឆ្នាំមុន ។ ការធ្លាក់ចុះនេះ ហាក់ដូចជាទាក់ទងនឹងចំនួនអ្នករត់ម៉ូតូឌុប ។ ក្នុងចំណោមអ្នករត់ម៉ូតូឌុបបានសំភាសន៍ មាន៩៧% ទទួលស្គាល់ថា មានចំនួនអ្នករត់ម៉ូតូឌុបកាន់តែច្រើនឡើងៗនៅទីក្រុង ។ លទ្ធផលនេះ គាំទ្រដោយអង្កេតដូចគ្នាដែលបង្ហាញថា អ្នករត់ម៉ូតូឌុប ៨០% មកពីតំបន់ជនបទ ហើយ ៩០% ជាអ្នករកចំណូលផ្គត់ផ្គង់គ្រួសារ ។

កម្មករសំណង់មានជំនាញ ជាក្រុមទី២ ដែលជួបការលំបាកច្រើន បន្ទាប់ពីអ្នករត់ម៉ូតូឌុប ។ ប្រាក់ចំណូលប្រចាំថ្ងៃរបស់ពួកគេ បន្តធ្លាក់ចុះ ៣ខែជាប់គ្នា អស់ ១៨% មកត្រឹម ១១.៧៥០រៀលនៅខែកុម្ភៈ ២០០៦ ធៀបនឹង ១៤.៤០០រៀល នៅខែដូចគ្នាកាលពីឆ្នាំមុន ។ ការធ្លាក់ចុះនេះ ហាក់ដូចជាបណ្តាលមកពីការថយចំនួនគំរោងសាងសង់បានអនុម័តដែលរាយការណ៍ដោយនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រក្រុងភ្នំពេញ ដោយមានការធ្លាក់ចុះអស់ ៣៣% ពីខែកុម្ភៈ ២០០៥ ដល់ខែកុម្ភៈ ២០០៦ ។ លើសពីនេះ អង្កេតបង្ហាញថា ៤០% នៃកម្មករសំណង់មានជំនាញ សុទ្ធតែនៅលីវ ប៉ុន្តែភាគច្រើនពុំអាចសន្សំបានទេ ពីព្រោះប្រាក់ចំណូលរបស់ពួកគេ ត្រូវយកទៅផ្គត់ផ្គង់ក្រុមគ្រួសារ ។ អង្កេតក៏បង្ហាញថា កម្មករសំណង់មានជំនាញ ៣០% បានបញ្ចប់មធ្យមសិក្សា ៥៨% បានបញ្ចប់បឋមសិក្សា និង ៨% មិនបានចូលរៀន ។

ប្រាក់ចំនូលប្រចាំថៃជាមធ្យមរបស់កម្មករកាត់ដេរ ក៏ធ្លាក់ចុះ ០,៣% ដែរធៀបនឹងកំឡុងពេលដូចគ្នាកាលពីមួយឆ្នាំមុន ។ រឿងនេះ អាចពាក់ព័ន្ធនឹងការកាត់បន្ថយម៉ោងធ្វើការបន្ថែមម៉ោងនិងកំណើនចំនួនកម្មករបណ្តេត ។ ទោះបីជាអ្នកឆ្លើយសំភាសន៍ភាគច្រើនត្អូញត្អែរថា ពួកគេមិនអាចសន្សំចំណូលដ៏តិចតួចនិងកំពុងធ្លាក់ចុះនេះក្តី ក៏កម្មករកាត់ដេរមួយចំនួនតូចលើកឡើងថា ពួកគេអាចសន្សំ និងប្រើប្រាស់ប្រាក់សន្សំនេះ សំរាប់ប្រកបរបររកស៊ី នៅពេលពួកគេឈប់ធ្វើការ ។ ជាទូទៅ កម្មករកាត់ដេរចំណាយ ២៩០០រៀលក្នុងមួយថ្ងៃសំរាប់ម្ហូបអាហារ ហើយចំណាយសរុបគឺប្រហែល ៣៣ដុល្លារក្នុងមួយខែ ។

ប្រាក់ចំណូលប្រចាំថ្ងៃជាមធ្យមរបស់អ្នកធាក់ស៊ីក្លូ ធ្លាក់ចុះមកត្រឹម ៧៩០០រៀល នៅខែកុម្ភៈ ។ ទោះបីជាមានអ្នកធាក់ស៊ីក្លូខ្លះលើកឡើងពីកំណើនប្រាក់ចំណូលក្តី ប្រាក់ចំណូលជាមធ្យមរបស់ពួកគេ ធ្លាក់ចុះអស់ ៨% ធៀបនឹងមួយឆ្នាំមុន ។ កំណើនចំនួនម៉ូតូកង់បី រឺ ធុកធុក ប្រហែលជាកត្តាចំបងនៃការថយចំណូលរបស់ពួកគេ ។ អ្នកធាក់ស៊ីក្លូធ្វើការប្រហែល ១០ម៉ោងក្នុងមួយថ្ងៃ និង ២៥ថ្ងៃក្នុងមួយខែ ហើយចំណាយអស់ ១២០.០០០រៀល ក្នុងមួយខែ មួយភាគធំទៅលើម្ហូបអាហារ ។

ប្រាក់ចំណូលពិតរបស់អ្នកលីសែងគឺ ៦៥០០រៀលក្នុងមួយថ្ងៃ រឺ ធ្លាក់ចុះ ៦% ធៀបនឹងពេលដូចគ្នា កាលពីឆ្នាំមុន ។ ក្នុងចំណោមកម្មករលីសែងសរុបបានសំភាសន៍ ៨៥% បានរាយការណ៍ថា ការងាររបស់ពួកគេមានលក្ខណៈបណ្តោះអាសន្ន និងមិនទៀងទាត់ ដោយអាស្រ័យលើតំរូវការរបស់អ្នកជួល ។ អង្កេតបង្ហាញថា អ្នកឆ្លើយសំភាសន៍ភាគច្រើន ជាអ្នកមកពីជនបទ ដោយសារគ្រួសារពួកគេជួបប្រទះកង្វះខាតស្បៀងអាហារ ហើយប្រហែលជា ៥០% មានវ័យជំទង់ ពី១៦ឆ្នាំ ដល់២៥ឆ្នាំ ។

ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នករើសសំរាមគឺ ៥០០០រៀល រឺ ៧,៥% ទាបជាងនៅពេលដូចគ្នាឆ្នាំមុន ។ រឿងនេះ បណ្តាលមកពីការធ្លាក់ចុះទាំងបរិមាណ និងថ្លៃសំរាមនៅកំឡុងពេលអង្កេត រួមផ្សំនឹងកំណើនចំនួនអ្នករើសសំរាម ដែលមកពីតំបន់ជនបទ ។

ទោះជាយ៉ាងណាក្តី ប្រាក់ចំណូលប្រចាំថៃជាមធ្យមរបស់អ្នកស៊ីឈ្នួលដកស្ទូងកើនបាន ៣,៣% ដល់ ៤១០០រៀល នៅខែកុម្ភៈ ធៀបនឹងពេលដូចគ្នាឆ្នាំមុន ។ កំណើននេះ ជាសំខាន់មានទំនាក់ទំនងនឹងការធ្លាក់ចុះចំនួនអ្នកស៊ីឈ្នួលដកស្ទូង ។ ពួកគេភាគច្រើន បានឈប់ស៊ីឈ្នួលដកស្ទូងដើម្បីទៅរកការងារផ្សេងៗនៅទីក្រុង ។ យោងតាមអង្កេត អ្នកស៊ីឈ្នួលដកស្ទូង ៨០% បានរាយការណ៍ថា ប្រាក់ចំណូលរបស់ពួកគេកើនឡើងបន្តិច ទោះបីជាការងារមានលក្ខណៈបណ្តោះអាសន្នក្តី ។ បន្ថែមលើនេះ អ្នកឆ្លើយសំភាសន៍ ៥០% លើកឡើងថា ពួកគេគ្មានដីកសិកម្មទេ រីឯ ៥០% ទៀតមានដីតិចជាងមួយហិកតា ។ ដូច្នេះ ពួកគេពឹងផ្អែកភាគច្រើនលើការលក់កំលាំងពលកម្មដើម្បីលើកស្ទួយជីវភាពរស់នៅ ។

*រៀបរៀងដោយ អ៊ូច ច័ន្ទតារាទី និង ប៊ុន ដូរីណា*

# តាមដានសេដ្ឋកិច្ច ~ អាំងឌីកាទ័រ

តារាង១. គំរោងវិនិយោគឯកជនដែលបានអនុម័ត ឆ្នាំ១៩៩៧-២០០៥

| | 1997* | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q4 | Q1 | Q2 | Q3 | Q4 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 65.6 | 51.6 | 63.9 | 9.8 | 5.6 | 38.9 | 3.7 | 0.0 | 3.2 | 4.0 | 10.4 | 9.1 |
| ឧស្សាហកម្ម | 512.4 | 650.5 | 162.6 | 109.4 | 99.8 | 57.4 | 142.6 | 16.4 | 418.8 | 62.1 | 349.7 | 82.0 |
| កាត់ដេរ | 97.0 | 126.5 | 67.7 | 35.2 | 23.0 | 18.0 | 74.8 | 12.7 | 44.9 | 23.2 | 56.5 | 27.3 |
| សេវាកម្ម | 166.5 | 154.7 | 222.6 | 150.0 | 111.4 | 143.3 | 167.7 | 0.0 | 53.3 | 30.0 | 44.1 | 28.1 |
| សណ្ឋាគារ និងទេសចរណ៍ | 41.5 | 112.0 | 171.8 | 79.8 | 71.9 | 45.1 | 118.6 | 0.0 | 46.4 | 0.0 | 33.6 | 22.6 |
| សរុប | 744.5 | 856.8 | 449.1 | 269.2 | 216.8 | 239.6 | 314.1 | 16.4 | 475.3 | 96.1 | 404.2 | 119.2 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | -80.0 | 2,798.2 | -79.8 | 320.6 | -70.5 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | - | 15.0 | -47.6 | -40.0 | -19.5 | 10.5 | 31.1 | -73.6 | 650.8 | -15.2 | 392.9 | 628.1 |

Source: Cambodian Investment Board. *Excluding expansion project approvals.

តារាង២. តំលៃគំរោងសំណង់នៅភ្នំពេញដែលបានអនុម័ត ឆ្នាំ១៩៩៧-២០០៥

| | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q4 | Q1 | Q2 | Q3 | Q4 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ, ផ្ទះ | 17.2 | 21.2 | 20.0 | 16.4 | 15.9 | 23.4 | 20.0 | 5.5 | 14.3 | 6.6 | 19.2 | 5.4 |
| ផ្ទះល្វែង | 19.3 | 227.3 | 290.5 | 174.8 | 167.8 | 179.9 | 91.6 | 46.3 | 48.6 | 69.1 | 41.3 | 45.1 |
| ផ្សេងៗ | 221.2 | 27.0 | 16.4 | 14.2 | 12.6 | 16.6 | 87.3 | 12.4 | 43.1 | 28.6 | 16.0 | 21.3 |
| សរុប | 257.7 | 275.4 | 326.8 | 205.4 | 196.2 | 219.8 | 198.9 | 64.1 | 106.1 | 104.4 | 76.5 | 71.8 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | -17.7 | 65.5 | -1.6 | -26.7 | -6.1 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | - | 6.9 | 18.7 | -37.2 | -4.5 | 12.0 | -9.5 | 28.6 | 45.5 | 114.8 | -1.8 | 12.0 |

Source: Department of Cadastre and Geography of the Municipality of Phnom Penh

តារាង៣. ការនាំចេញ និងនាំចូល ឆ្នាំ១៩៩៧-២០០៥

| | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q4 | Q1 | Q2 | Q3 | Q4 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 493.4 | 784.4 | 941.1 | 1,056.2 | 1,268.2 | 1,453.2 | 1,708.1 | 545.1 | 463.0 | 515.0 | 730.0 | 644.8 |
| រួមមាន: សំលៀកបំពាក់ | 227.2 | 378.0 | 554.0 | 962.1 | 1,202.2 | 1,355.8 | 1,628.4 | 520.3 | 444.9 | 497.6 | 709.8 | 601.0 |
| - ទៅសហរដ្ឋអាមេរិក | 107.2 | 74.1 | 486.0 | 714.1 | 840.9 | 943.4 | 1,099.8 | 321.2 | 312.5 | 335.9 | 489.5 | 408.1 |
| - ទៅសហគមន៍អឺរ៉ុប | - | - | - | 228.1 | 323.3 | 356.3 | 414.7 | 159.1 | 89.2 | 106.0 | 162.5 | 145.3 |
| - ប្រទេសផ្សេងទៀត | 120.0 | 82.0 | 68.0 | 19.9 | 38.0 | 56.1 | 113.8 | 40.0 | 43.1 | 55.7 | 57.8 | 47.5 |
| កសិកម្ម | - | - | - | 94.2 | 66.0 | 97.3 | 79.7 | 24.8 | 18.1 | 17.3 | 20.2 | 43.8 |
| - កៅស៊ូ | - | - | - | 29.6 | 25.9 | 29.7 | 35.1 | 12.0 | 7.3 | 6.2 | 9.8 | 13.4 |
| - ឈើ | - | - | - | 32.9 | 22.3 | 16.0 | 10.2 | 2.4 | 3.3 | 2.9 | 2.1 | 2.0 |
| - ត្រី | - | - | - | 5.4 | 6.0 | 4.3 | 2.8 | 4.4 | 1.5 | 1.1 | 0.8 | 6.6 |
| - ផ្សេងៗ | - | - | - | 26.2 | 11.8 | 47.4 | 31.6 | 6.0 | 6.0 | 7.1 | 7.5 | 21.9 |
| ការនាំចូលសរុប | 1,094.5 | 1,112.2 | 1,237.4 | 1,417.7 | 1,501.4 | 1,674.1 | 1,824.9 | 548.1 | 520.7 | 666.4 | 632.3 | 691.1 |
| រួមមាន: - សាំង | - | - | - | - | - | 26.0 | 33.2 | 7.8 | 10.3 | 9.3 | 9.9 | 10.7 |
| - ម៉ាស៊ូត | - | - | - | - | - | 102.0 | 109.6 | 23.5 | 21.6 | 25.8 | 24.6 | 21.1 |
| - សំភារៈសំណង់ | - | - | - | - | - | 97.4 | 80.8 | 26.5 | 32.3 | 37.1 | 38.7 | 26.2 |
| - ផ្សេងៗ | - | - | - | - | - | 1,448.7 | 1,601.3 | 490.3 | 456.5 | 594.2 | 559.1 | 633.1 |
| ជញ្ជីងពាណិជ្ជកម្ម | -601.2 | -327.8 | -296.3 | -361.5 | -233.2 | -220.9 | -116.8 | -3.0 | -57.7 | -151.4 | 97.7 | -46.3 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | - | - | - | - | - | - | - | -19.2 | -14.5 | 11.8 | 42.6 | -15.3 |
| ការនាំចេញសរុប | - | - | - | - | - | - | - | -18.5 | -15.1 | 11.2 | 41.7 | -11.7 |
| ការនាំចូលសរុប | - | - | - | - | - | - | - | 4.5 | -5.0 | 28.0 | -5.1 | 9.3 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | 188.0 | 66.4 | 47.0 | 74.0 | 24.9 | 12.8 | 20.1 | 16.0 | 16.0 | 3.8 | 10.3 | 15.5 |
| ការនាំចេញសរុប | 27.5 | 59.0 | 20.0 | 12.2 | 20.1 | 14.6 | 17.5 | 14.6 | 15.9 | 4.1 | 9.2 | 18.3 |
| ការនាំចូលសរុប | -1.8 | 1.6 | 11.3 | 14.6 | 5.9 | 11.5 | 9.0 | 12.5 | 13.7 | 9.9 | 20.5 | 26.1 |

Sources: Department of Trade Preferences Systems, MOC and Customs and Excise Department, MEF. Import data include tax exemption imports.

# តារាងសេដ្ឋកិច្ច _ អាំងឌីកាទ័រ

តារាង៤. ចំនួនអ្នកដំណើរបរទេសមកដល់ក្នុងប្រទេសកម្ពុជា ឆ្នាំ១៩៩៧-២០០៥

| | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q4 | Q1 | Q2 | Q3 | Q4 |
| | អ្នកដំណើរ ( ពាន់នាក់) | | | | | | | | | | | |
| តាមផ្លូវអាកាស | - | 186.3 | 262.9 | 351.7 | 408.4 | 523.0 | 456.0 | 201.5 | 231.7 | 169.8 | 202.8 | 251.5 |
| តាមផ្លូវគោក និងផ្លូវទឹក | - | 100.2 | 104.8 | 114.7 | 196.5 | 263.5 | 245.0 | 177.3 | 148.9 | 124.0 | 120.4 | 164.5 |
| សរុប | 218.8 | 286.5 | 367.7 | 466.4 | 604.9 | 786.5 | 701.0 | 378.8 | 380.6 | 293.8 | 323.2 | 416.0 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | 66.1 | 0.5 | -22.8 | 10.0 | 28.7 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -16.0 | 30.9 | 28.3 | 26.8 | 29.7 | 30.0 | -10.9 | 70.1 | 49.6 | 51.6 | 41.8 | 9.8 |

ប្រភព: ក្រសួងទេសចរណ៍ ។ Source: Ministry of Tourism

តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានជាសាច់ប្រាក់ ឆ្នាំ១៩៩៧-២០០៥ ( ពាន់លានរៀល)

| | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q4 | Q1 | Q2 | Q3 | Q4 |
| ចំណូលសរុប | 880 | 920 | 1326 | 1,528 | 1,529 | 1,744 | 1,765 | 662.2 | 551.6 | 621.9 | 624.0 | 827.8 |
| ចំណូលចរន្ត | - | - | - | - | 1,521 | 1,728 | 1,733 | 657.7 | 551.3 | 611.5 | 609.5 | 701.6 |
| ចំណូលពន្ធ | 596 | 676 | 956 | 1,096 | 1,096 | 1,227 | 1,220 | 485.7 | 455.1 | 466.0 | 436.2 | 553.8 |
| ពន្ធគយ | 348 | 376 | 432 | 376 | 376 | 424 | 395 | 168.0 | 129.4 | 129.7 | 123.7 | 189.8 |
| ចំណូលមិនមែនពន្ធ | 272 | 204 | 348 | 424 | 424 | 501 | 513 | 172.1 | 96.2 | 145.5 | 173.2 | 147.8 |
| អាជីវកម្មព្រៃឈើ | 36 | 20 | 36 | 28 | 29 | 15 | 7.0 | 0.5 | 1.3 | 1.5 | 0.3 | 0.1 |
| ប្រៃសណីយ៍ និងទូរគមនាគមន៍ | 84 | 88 | 108 | 124 | 122 | 123 | 120 | 26.3 | 21.9 | 32.0 | 30.9 | 38.0 |
| ចំណូលជាមូលធន | 12 | 36 | 12 | 8 | 9 | 16 | 31 | 4.5 | 0.3 | 10.4 | 14.6 | 126.3 |
| ចំណាយសរុប | 1,260 | 1,296 | 1,792 | 2,332 | 2,332 | 2,948 | 2,757 | 909.3 | 706.3 | 713.7 | 912.9 | 1022.4 |
| ចំណាយជាមូលធន | 452 | 368 | 624 | 976 | 977 | 1,388 | 1,171 | 293.5 | 326.3 | 315.9 | 335.4 | 373.8 |
| ចំណាយចរន្ត | 808 | 980 | 1,164 | 1,356 | 1,355 | 1,560 | 1,586 | 615.8 | 380.0 | 397.8 | 577.0 | 648.6 |
| អប់រំ និងសុខាភិបាល | 128 | 132 | 280 | 344 | 343 | 454 | 473 | 290.0 | 52.5 | 92.3 | 202.1 | 228.4 |
| ការពារជាតិ និងសន្តិសុខ | 420 | 448 | 464 | 404 | 405 | 438 | 411 | 197.8 | 74.9 | 73.9 | 116.7 | 185.8 |
| ក្រសួងផ្សេងៗទៀត | 260 | 332 | 412 | 636 | 637 | 668 | 702 | 130.6 | 252.6 | 231.7 | 258.2 | 234.4 |
| ឱនភាពជាទូទៅ | -380 | -380 | -476 | -804 | -803 | -1,204 | -992 | -247.1 | -154.7 | -91.9 | -288.3 | -194.6 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 444 | 268 | 416 | 768 | 766 | 1,249 | 886 | 238.7 | 266.7 | 255.7 | 335.8 | 292.5 |
| ហិរញ្ញប្បទានក្នុងស្រុក | -64 | 112 | 60 | 36 | 37 | -45 | 106 | 8.4 | -111.9 | -163.9 | -47.5 | -97.9 |

Provisional for 2004 and 2005. Source: Ministry of Economy and Finance

តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) អត្រាប្តូរប្រាក់ និងថ្លៃមាស ឆ្នាំ១៩៩៧-២០០៥ ( មធ្យមភាគតាមការិយបរិច្ឆេទ)

| | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q4 | Q1 | Q2 | Q3 | Q4 |
| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ( បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ខេត្ត* | - | - | 5.8 | 5.4 | -0.1 | 0.9 | 4.4 | 23.0 | 14.3 | 7.9 | 3.6 | 4.1 |
| ភ្នំពេញ - ទំនិញគ្រប់ប្រភេទ | 8.0 | 14.8 | 4.0 | -0.8 | 0.2 | 3.3 | 1.1 | 5.8 | 5.6 | 6.4 | 4.6 | 6.6 |
| ភ្នំពេញ - ម្ហូបអាហារ | 6.7 | 14.1 | 7.6 | -3.4 | -2.5 | 1.8 | 1.5 | 9.1 | 7.9 | 9.8 | 6.0 | 10.6 |
| ភ្នំពេញ - ដឹកជញ្ជូន | 19.5 | 15.1 | 3.5 | 6.6 | -4.2 | 0.3 | 4.9 | 14.5 | 12.3 | 11.1 | 11.9 | 10.2 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ ( តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ* | - | - | - | 3,840.8 | 3,916.3 | 3,912.1 | 3,973.3 | 4,034.7 | 4,027.0 | 4,054.3 | 4,134.3 | 4,154.3 |
| រៀលក្នុង ១ បាតថៃ* | - | - | - | 95.8 | 88.2 | 91.1 | 95.8 | 100.1 | 104.4 | 101.3 | 100.2 | 101.4 |
| រៀលក្នុង ១០០ ដុងវៀតណាម* | - | - | - | 27.1 | 26.6 | 25.6 | 25.6 | 25.3 | 25.1 | 25.3 | 25.9 | 26.1* |
| ថ្លៃមាស ( ដុល្លារក្នុង១ជី) | 46.3 | 40.4 | 36.0 | 33.3 | 32.8 | 36.8 | 41.4 | 47.0 | 52.6 | 52.5 | 55.4 | 57.0 |
| ថ្លៃម៉ាស៊ូត ( រៀល/លីត្រ) | 779 | 883 | 1,065 | 1,105 | 1,329 | 1,521 | 1,508 | 2,150 | 2,350 | 2,500 | 2,767 | 2,921 |
| ថ្លៃសាំង ( រៀល/លីត្រ) | 1,118 | 1,378 | 1,613 | 1,760 | 2,113 | 2,084 | 2,150 | 2,950 | 3,050 | 3,300 | 3,633 | 3,750 |

* October-November 2005. Sources: CDRI, IMF, NIS, Ministry of Planning, Ministry of Economy and Finance

*តពីទំព័រទី ៨* **លទ្ធផលសេដ្ឋកិច្ចនៃ...**

គំរូនេះ រចនាឡើងជាសំខាន់ សំរាប់បំរើតំរូវការអ្នកស្រាវជ្រាវដែលមានចំនេះដឹងបច្ចេកទេសសមស្រប អំពីប៉ារ៉ាម៉ែត្រលូតលាស់ឈើ ពីសេដ្ឋកិច្ចបរិស្ថាន និងរបៀបប្រើកម្មវិធី Excel ។ គំរូនេះអាចរចនាឱ្យកាន់តែងាយប្រើថែមទៀត ប៉ុន្តែវានឹងមានលក្ខណៈស្ដាទិក ហើយមិនអាចកែតំរូវឱ្យស៊ីគ្នា នឹងស្ថានភាពនៅមូលដ្ឋានដែលប្រែប្រួលទៅតាមពេលវេលានោះទេ ។ គំរូសាមញ្ញអាចផ្អែកលើទិន្នន័យស្រាវជ្រាវដែលគួរឱ្យទុកចិត្ត ដើម្បីធ្វើការសន្មតឱ្យបានសមស្របពីកត្តាចំបងៗដូចជាកំរិតលូតលាស់ និងទិន្នផលជាដើម ។ ដូចបានបញ្ជាក់ខាងលើ នាបច្ចុប្បន្នពុំមានទិន្នន័យបែបនេះទេសំរាប់កម្ពុជា ដូច្នេះគំរូសាមញ្ញ អាចមិនសូវត្រឹមត្រូវ ។ គំរូនេះបានកសាងឡើងជាឧបករណ៏ស្រាវជ្រាវ ដោយមានគំនិតថ្មីងថ្លែងបែបនេះឯង ។ អ្នកកសាងគោលនយោបាយអាចពិនិត្យពី NPV ដែលគណនាឃើញ ប៉ុន្តែត្រូវមានជំនាញជាក់លាក់ខាងសេដ្ឋកិច្ចបរិស្ថាន និងការធ្វើគំរូលូតលាស់ឈើ ទើបអាចកែតំរូវគំរូ ធ្វើការបកស្រាយពីភាពអាចទុកចិត្តបាននៃលទ្ធផលរកឃើញថ្មីៗនិងយកវាទៅប្រើក្នុងការផ្ដល់អនុសាសន៏ខាងគោលនយោបាយ ។

ទៅអនាគត គំរូនេះអាចយកទៅកែសំរួលថែមទៀតឱ្យទៅជាឧបករណ៏ធ្វើផែនការសំរាប់ ការប្រើប្រាស់ធនធានធម្មជាតិដោយចីរភាព ។ម្យ៉ាងទៀត លក្ខណៈស្មុគស្មាញនៃការធ្វើគំរូនេះ បង្ហាញពីតំរូវការតភ្ជាប់ការងារគ្រប់គ្រងធនធានធម្មជាតិ ទៅនឹងការកសាងសមត្ថភាពអ្នកធ្វើផែនការ និងអ្នកស្រាវជ្រាវខាងធនធានធម្មជាតិកម្ពុជា ។ តាមមធ្យោបាយនេះ គេនឹងអាចកសាងទិន្នន័យជាតិកាន់តែគួរឱ្យទុកចិត្តបានថែមទៀត ពីទិន្នផលសក្ដានុពលនៅតាមតំបន់ផ្សេងៗ ហើយអ្នកធ្វើផែនការខាងធនធានធម្មជាតិក៏អាចកសាងគំរូផ្ទាល់របស់ខ្លួនដោយផ្អែកលើការស្រាវជ្រាវដ៏រឹងប៉ឹង ដែលមានទាំងការកំនត់ និងការផ្ដល់អាទិភាពដល់តំលៃប្រយោលផង ។

## ឯកសារយោង


Bann, C. (1997), An Economic Analysis of Tropical Forest Land Use Options, Ratankiri Province, Cambodia. (EEPSEA Research Report) Available at http://www.idrc.ca/en/ev-8446-201-1-DO_TOPIC.html

Barr, C. & C. Cossalter (2004), "China's development of a plantation based pulp industry: government policies, financial incentives and investment trends", *International Forestry Review 6* (3–4) pp. 267–281

Brown, S. (1997), *Estimating Biomass and Biomass Change of Tropical Forests: a Primer*, FAO Forestry Paper 134 (Rome: FAO—Food and Agriculture Organisation of the United Nations) Available at http://www.fao.org/docrep/W4095E/W4095E00.htm

FA (2003), *Forest Systems Research and Modeling Handbook, Document 4; Development of Growth and Yield Studies and Establishment of Permanent Sample Plots.* (Forest Concession Management and Control Pilot Project, Forest Administration, Ministry of Agriculture, Forestry and Fisheries, Cambodia)

Gou, Z., X. Xiao, Y. Gan, & Y. Zheng (2001), "Ecosystem functions, services and their values—a case study in Xingshan County, China", *Ecological Economics* 38 (1) pp. 141–154

Gregersen, H.M., J.E.M. Arnold, A.L. Lundgren & A. Contreras-Hermosilla (1995), *Valuing forests: context, issues and guidelines,* FAO Forestry Paper 127 (Rome: FAO)

Lopez, T.T.D. (2003) "Economics and stakeholders of Ream National Park, Cambodia", *Ecological Economics* 46, pp. 269–282.


តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ១៩៩៧-២០០៥ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q4 | Q1 | Q2 | Q3 | Q4 |
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 1,177 | 1,726 | 2,019 | 2,589 | 3,080 | 3,737 | 4,027 | 4,797 | 4,883 | 5,084 | 5,391 | 5,475 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -114 | -496 | -576 | -759 | -876 | -849 | -698 | -467 | -385 | -455 | -397 | -450 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | 54 | 178 | 103 | 3 | -75 | -119 | -128 | -209 | -252 | -343 | -404 | -421 |
| ឥណទានចំពោះផ្នែកឯកជន | 637 | 655 | 763 | 898 | 936 | 1,059 | 1,337 | 1,817 | 1,983 | 2,166 | 2,386 | 2,394 |
| រូបិយវត្ថុទូទៅ M2 | 1,063 | 1,230 | 1,443 | 1,831 | 2,204 | 2,888 | 3,328 | 4,329 | 4,498 | 4,629 | 4,994 | 5,025 |
| រូបិយវត្ថុ M1 | 385 | 543 | 531 | 540 | 609 | 813 | 937 | 1,153 | 1,198 | 1,215 | 1,279 | 1,323 |
| រូបិយវត្ថុផ្សេងៗ | 678 | 687 | 911 | 1,291 | 1,594 | 2,075 | 2,391 | 3,176 | 3,300 | 3,414 | 3,715 | 3,702 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 16.6 | 15.7 | 17.3 | 26.9 | 20.4 | 31.0 | 15.2 | 30.0 | 22.9 | 20.4 | 19.8 | 16.1 |
| រូបិយវត្ថុ M1 | 17 | 41 | -2.2 | 1.7 | 12.8 | 33.5 | 15.3 | 23.0 | 19.0 | 16.8 | 18.6 | 14.7 |
| រូបិយវត្ថុផ្សេងៗ | 16.3 | 1.3 | 32.6 | 41.7 | 23.5 | 30.2 | 15.2 | 32.8 | 20.3 | 21.7 | 20.2 | 16.6 |

Source: National Bank of Cambodia

តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ

| | ចំណូលប្រចាំថៃ (ជារៀល) | | | | | | | | | បំរែបំរួលធៀបនឹងឆ្នាំមុន (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2000 | 2002 | 2003 | 2004 | 2005 | | | | 2006 | 2004 | 2005 | 2006 |
| | Nov | | | | Feb | May | Aug | Nov | Feb | | | Feb |
| អ្នកធាក់ស៊ីក្លូ | 7,594 | 8,975 | 8,572 | 7,614 | 8,527 | 7,726 | 7,857 | 7,768 | 7,873 | -11.2 | 4.7 | -7.7 |
| អ្នកលីសែង | 6,233 | 7,044 | 6,676 | 6,895 | 6,933 | 7,056 | 6,000 | 6,473 | 6,519 | 3.3 | -4.0 | -6.0 |
| អ្នកលក់បន្លែតូចតាច | 5,256 | 6,566 | 6,532 | 6,947 | 6,385 | 8,574 | 5,938 | 8,385 | 6,186 | 6.4 | 5.4 | -3.3 |
| អ្នករើសអេតចាយ | 2,718 | 3,685 | 3,944 | 4,446 | 5,382 | 5,270 | 4,335 | 4,801 | 4,984 | 12.7 | 11.3 | -7.4 |
| អ្នកបំរើតាមភោជនីយដ្ឋាន* | 2,111 | 4,365 | 4,932 | 4,448 | 4,470 | 4,287 | 4,648 | 3,893 | 4,670 | -9.8 | -2.8 | 4.5 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 4,198 | 4,304 | 4,177 | 4,139 | 3,997 | 3,822 | 4,009 | 4,224 | 4,127 | -0.9 | -3.0 | 3.3 |
| កម្មកររោងចក្រកាត់ដេរ | 6,701 | 8,904 | 9,577 | 9,277 | 9,213 | 7,235 | 8,756 | 8,659 | 9,184 | -3.1 | -8.7 | -0.3 |
| អ្នករត់ម៉ូតូឌុប | 8,610 | 12,184 | 10,092 | 9,204 | 11,767 | 11,130 | 9,406 | 9,645 | 8,884 | -8.8 | 14.8 | -24.5 |
| កម្មករសំណង់គ្មានជំនាញ | 5,399 | 6,453 | 6,558 | 6,382 | 5,747 | 8,130 | 6,069 | 6,691 | 5,974 | -2.7 | 4.3 | 3.9 |
| កម្មករសំណង់មានជំនាញ | 13,127 | 12,605 | 13,111 | 12,679 | 14,367 | 12,230 | 10,273 | 11,253 | 11,750 | -3.3 | -4.9 | -18.2 |

សំគាល់: ចំនួលអ្នកបំរើតាមភោជនីយដ្ឋាន អ្នកស៊ីឈ្នួលធ្វើស្រែ កម្មករកាត់ដេរ អ្នករត់ម៉ូតូឌុប និងកម្មករសំនង់មាននិងគ្មានជំនាញ ចាប់ធ្វើអង្កេតពីខែកុម្ភៈ២០០០ ។ *ចំនួលអ្នកបំរើតាមហាងមិនរាប់បញ្ចូល អាហារ និងការស្នាក់នៅដែលម្ចាស់ភោជនីយដ្ឋានផ្ដល់ឱ្យទេ ។

គេមានមោទនភាពហើយខ្ញុំក៏មានមោទនភាពចំពោះពួកគេដែរ ។ បច្ចុប្បន្ន បុគ្គលិកខ្មែរបានកាន់កាប់តំណែងគ្រប់គ្រងក្នុងគ្រប់កម្មវិធីទាំងអស់ ហើយ បុគ្គលិកបរទេសបំពេញតួនាទីជាទីប្រឹក្សាវិញ ។ បុគ្គលិកខ្មែរ ក៏កំពុងឈាន បណ្ដើរៗទៅកាន់តំណែងគ្រប់គ្រងសំខាន់ៗនៅផ្នែកដទៃទៀតដែរ ។

បច្ចុប្បន្ន មិនទាន់សំបូរអ្នកស្រាវជ្រាវមានបទពិសោធន៍ខ្ពស់ទេ ។ នេះជាបញ្ហាចំបងមួយចំពោះ វិបសអ ដែលត្រូវធ្វើការកសាងសមត្ថភាព ផ្ទៃក្នុងជាប់រហូត ព្រមទាំងត្រូវប្រឈមនឹងការបាត់បង់បុគ្គលិកមានបទ ពិសោធន៍ ដែលចេញទៅបំរើការឱ្យអង្គការ និងវិទ្យាស្ថានផ្សេងទៀត ។ ប៉ុន្តែនៅពេលខ្ញុំសំឡឹងមើលជុំវិញខ្លួន ហើយឃើញអតីតបុគ្គលិក វិបសអ ជាពិសេស ឯ.ឧ ហង់ ជួនណារ៉ុន ជាសហប្រធាននៃក្រុមប្រឹក្សាភិបាល វិបសអ និងការងារដែលពួកគេបំពេញក្នុងមុខតំណែងខ្ពស់ៗនៅកន្លែង ផ្សេងទៀត ខ្ញុំគិតថា នេះគឺជាជោគជ័យមួយថែមទៀតរបស់ វិបសអ ។

ពួកគេនិយាយថា លទ្ធផលការងារគឺជារង្វាន់ ហើយខ្ញុំឃើញថា ពិត ដូច្នេះមែនចំពោះការងាររបស់ខ្ញុំនៅ វិបសអ ។ ពេលខ្លះ ជាពិសេសក្នុង កំឡុងអន្តរកាលការដឹកនាំនៅឆ្នាំ២០០៣ គឺមានការងារលំបាកៗច្រើន ប៉ុន្តែខ្ញុំមានសេចក្ដីរីករាយ និងរៀនសូត្របានមួយចំនួនពីការងារដែល ខ្ញុំចូលពាក់ព័ន្ធក្នុងរយៈ ៦ឆ្នាំកន្លងទៅនេះ ។ ខ្ញុំពេញចិត្តខ្លាំងណាស់ នឹង ការពិភាក្សាបែបស្ថាបនា ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងសូម អរគុណដល់សមាជិកទាំងអស់ទាំងពីមុននិងបច្ចុប្បន្នក្នុងក្រុមប្រឹក្សាភិបាល ចំពោះការចូលរួមចំណែករបស់ពួកគេ ។ បច្ចុប្បន្ន ក្រុមប្រឹក្សាភិបាលកំពុង ស្ថិតក្នុងដំណាក់កាលអន្តរកាល ហើយខ្ញុំជឿជាក់ថា សមាសភាពថ្មីនឹងផ្ដល់ ការគាំទ្រ និងការណែនាំយ៉ាងល្អប្រសើរ សំរាប់ឆ្នាំខាងមុខទៀត ។

ពិសេសបំផុត ខ្ញុំគិតថា មានសំណាងខ្លាំងណាស់ដែលបានឃើញផ្ទាល់ ភ្នែកពីការរីកលូតលាស់សមត្ថភាពបុគ្គលិកខ្មែរក្មេងៗ និងមោះមុត ដែល កំពុងចូលរួមចំណែកយ៉ាងធំធេងដល់ការអភិវឌ្ឍន៍ប្រទេសជាតិខ្លួន ។ ខ្ញុំ សូមអរគុណដល់ពួកគេ និងដល់ថ្នាក់គ្រប់គ្រង សំរាប់អ្វីៗទាំងអស់ដែលខ្ញុំ អាចរៀនសូត្របាន ។ ខ្ញុំសូមជូនពរដល់គ្រប់ៗគ្នា ដែលជាប់ពាក់ព័ន្ធនឹង វិបសអ បុគ្គលិកនិងថ្នាក់គ្រប់គ្រងរបស់វិទ្យាស្ថាន ក្រុមប្រឹក្សាភិបាល អ្នក ផ្ដល់ជំនួយ និងដៃគូរបស់វិទ្យាស្ថាន ឱ្យទទួលជោគជ័យជារៀងរហូត ។

## ផ្នែកស្រាវជ្រាវ

នាពេលថ្មីៗ វិបសអ បានទទួលយោបល់ជាវិជ្ជមានចំពោះសេចក្ដីព្រាង របាយការណ៍ស្ដីពីការសិក្សាលើ "ការពិនិត្យមើលផលប៉ះពាល់លើភាព ក្រីក្រ ពីសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់នៅមហាអនុតំបន់មេគង្គ (RETA)" ។ ក្រុម RETA នៃ វិបសអ បានចូលរួមក្នុងសិក្ខាសាលានៅ ទីស្នាក់ការកណ្ដាល ADB នៅក្រុងម៉ានីល ដើម្បីពិភាក្សាជាមួយវិទ្យាស្ថាន ស្រាវជ្រាវរបស់ឡាវ ថៃ និងវៀតណាម ដែលសហការក្នុងគំរោងនេះ ដែរ ។ នៅកម្ពុជា វិបសអ ធ្វើការរួមគ្នាជាមួយវិជ្ជាស្ថានជាតិស្ថិតិ ។ ខណៈនេះ ការសិក្សាសំខាន់ៗ ២ ទៀតរបស់ វិបសអ ទាក់ទិននឹងភាពក្រីក្រ គឺការចាកចេញឱ្យផុតពីភាពក្រីក្រ (MOPS) និងការវាយតំលៃភាពក្រីក្រ ដោយមានការចូលរួម (PPA) កំពុងឈានដល់ដំណាក់កាលបញ្ចប់ហើយ ។

នាពេលថ្មីៗនេះ វិបសអ ទទួលដំណឹងពី AusAid ថា សំណើធ្វើការ ស្រាវជ្រាវលើការគ្រប់គ្រងធនធានទឹក និងកម្មវិធីកសាងសមត្ថភាព បានអនុម័តហើយ ។ កម្មវិធីមានរយៈពេល ៥ឆ្នាំនេះ គ្រោងចាប់ផ្ដើមនៅ ថ្ងៃ ០១ កក្កដា ២០០៦ ដោយរួមសហការជាមួយសាកលវិទ្យាល័យស៊ីដនី និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។អ្នកពាក់ព័ន្ធសំខាន់ៗក្នុងជួររដ្ឋាភិបាល រួមមានក្រសួងធនធានទឹក និងឧតុនិយម និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ការស្រាវជ្រាវដំបូងផ្ដោតលើវិស័យធារាសាស្ត្រ ។

ក្រុមបណ្ដាញវិភាគអភិវឌ្ឍន៍ (DAN) នៃ វិបសអ កំពុងចូលរួមក្នុងការ សិក្សាករិតតំបន់ស្ដីពីទេសចរណ៍អំណោយផលដល់អ្នកក្រ នៅមហាអនុ តំបន់មេគង្គ ។ វិបសអ ជាអ្នកជួយដឹកនាំបំផុសគំនិត និងរៀបចំការងារក្នុង គំរោងនេះ ។ កិច្ចប្រជុំ DAN ប្រចាំតំបន់នៅក្រុងលួងប្រាបាងប្រទេសឡាវ បង្ហាញថា គោលនយោបាយអភិវឌ្ឍន៍ទេសចរណ៍ គឺជាចំណែកមួយកាន់តែ សំខាន់ឡើងនៃយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ។ នៅកម្ពុជា វិបសអ កំពុងសហការជាមួយមជ្ឈមណ្ឌលសំរាប់ការស្រាវជ្រាវជាន់ខ្ពស់ (CAS) ដើម្បីបញ្ចប់ការចុះអង្កេតសំរាប់ករណីសិក្សាមួយនៅខេត្តសៀមរាប ។

នៅខែមីនា វិបសអ បានបោះពុម្ពផ្សាយឯកសារសង្ខេបគោលនយោ បាយ ៤ថ្មីទៀត រៀបរៀងឡើងដោយផ្អែកធនធានធម្មជាតិ និងបរិស្ថាន ។ ឯកសារនីមួយៗមាន ៤ទំព័រ និងអធិប្បាយពីបញ្ហាជាក់លាក់មួយទាក់ ទិននឹងគោលនយោបាយ និងរបៀបរបបគ្រប់គ្រងព្រៃឈើនៅកម្ពុជា ។ ឯកសារទាំងនេះបោះពុម្ពជាភាសាខ្មែរ និងអង់គ្លេស ដើម្បីផ្សព្វផ្សាយ អោយបានទូលាយ ។ ឯកសារបានទទួលការអបអរសាទរពីសំណាក់មន្ត្រី រាជការ អ្នកផ្ដល់ជំនួយ និងអង្គការសង្គមស៊ីវិល ហើយក្លាយជាគំរូមួយសំ រាប់ឱ្យផ្នែកស្រាវជ្រាវឯទៀតបង្កើនគុណភាពរបាយការណ៍ខ្លួន ។ វិបសអ គ្រោងបោះពុម្ពផ្សាយរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ លេខ២ នៅខែកញ្ញា ២០០៦ ។ របាយការណ៍ជាភាសាអង់គ្លេស នឹងចេញផ្សាយព្រមគ្នាជាមួយ ឯកសារសង្ខេបគោលនយោបាយជាភាសាខ្មែរ ដើម្បីផ្សព្វផ្សាយដល់អ្នក អានឱ្យកាន់តែច្រើន ពិសេសអ្នកពាក់ព័ន្ធនានាដែលប្រើប្រាស់ភាសាខ្មែរ ។

## មជ្ឈមណ្ឌលដើម្បីសន្តិភាព និងអភិវឌ្ឍន៍ (CPD)

ក្នុងរយៈ៦ខែកន្លងមកនេះអ្នកស្រាវជ្រាវវិបសអបានបង្កើតឧបករណ៍វាយ តំលៃមួយសំរាប់វិភាគពីតំរូវការវគ្គបណ្ដុះបណ្ដាល ។ ឧបករណ៍នេះបាន ប្រើប្រាស់ជាលើកទី១ នៅខេត្តក្រចេះ នៅខែកុម្ភៈ ដែលនាំឱ្យមានការបើក វគ្គបណ្ដុះបណ្ដាលពីការគ្រប់គ្រងទំនាស់ដល់មន្ត្រីមូលដ្ឋាន ។ ក្នុងកម្មវិធី បណ្ដុះបណ្ដាលឆ្នាំ២០០៦ មួយខ្សែខាងកសាងសន្តិភាព ក្រុម CPD បាន បញ្ចប់ហើយនូវវគ្គ ១ ក្នុងចំណោម ៤វគ្គ សំរាប់សិក្ខាកាម ២៥នាក់ មក ពីមូលដ្ឋានខុសៗគ្នា ។CPD កំពុងសរុបពីតំរូវការវគ្គសិក្សា និងទីកន្លែងសំ រាប់កម្មវិធីបណ្ដុះបណ្ដាលពីការកសាងសន្តិភាពនិងដោះស្រាយទំនាស់ ។

នៅកំឡុងពេលដូចគ្នាCOPCEL បានបើកកិច្ចប្រជុំCOPCEL នៅ៤ខេត្ត (កណ្ដាល មណ្ឌលគីរី ស្ទឹងត្រែង និងរតនគីរី) កិច្ចប្រជុំ COPCEL ស្នូលចំនួន ៥ និងកិច្ចប្រជុំ COPCEL ទូលាយចំនួន ២ ។ នៅក្នុងកិច្ចប្រជុំទាំងនេះ អ្នក ចូលរួមអាចរកឃើញ និងពិភាក្សាអំពីបញ្ហាជាច្រើនទាក់ទិននឹងការបោះ ឆ្នោត ។ របាយការណ៍របស់ COPCEL បានជួយផ្សព្វផ្សាយពីការព្រួយបារម្ភ របស់តួអង្គផ្សេងៗក្នុងការបោះឆ្នោតនៅកម្ពុជា ។

## ព័ត៌មានថ្មីៗ ពី វបសអ

# ការវាយតំលៃបំរែបំរួល និងការរីកចំរើននៅ វបសអ ដោយ Jenny Pearson អតីតសហប្រធាននៃក្រុមប្រឹក្សាភិបាល



ឯ.ឧ ហង់ ជួនណារ៉ុន សហប្រធាននៃក្រុមប្រឹក្សាភិបាលនៅ វបសអ អរគុណ លោកស្រី Jenny Pearson អតីតសហប្រធាន ចំពោះការចូលរួមចំណែកដល់ការអភិវឌ្ឍន៍ វបសអ នាពិធីជប់លៀងទទួលក្រុមប្រឹក្សាភិបាលរៀបចំដោយ Larry Strange នាយកប្រតិបត្តិ វបសអ

នៅចុងបញ្ចប់នៃសកម្មភាពនីមួយៗ គឺជាវេលាដ៏ប្រសើរសំរាប់ធ្វើការត្រិះរិះពិចារណា ហើយខ្ញុំក៏ដូចគ្នាដែរ បានបញ្ចប់នៃរយៈ ២អាណត្តិ ក្នុងក្រុមប្រឹក្សាភិបាល វបសអ ។ នៅកំឡុងពេល ៦ឆ្នាំ ដែលខ្ញុំធ្វើជាសហប្រធាន មានព្រឹត្តិការណ៍គួរឱ្យចាប់អារម្មណ៍ជាច្រើនបានកើតឡើង ។ នៅឆ្នាំ២០០០ វបសអ ដែលមានបុគ្គលិកប្រហែល ៤០នាក់ កំពុងចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្រដំបូងរបស់វិទ្យាស្ថាន ។ ពេលនោះ កម្មវិធីបណ្តុះបណ្តាលចុងក្រោយគឺ ផ្នែកភាសាអង់គ្លេស ទើបនឹងបញ្ចប់ ហើយវិទ្យាស្ថានកំពុងស្វែងរកវិធីកសាងកម្មវិធីស្រាវជ្រាវ ។ ក្នុងពេលជាមួយគ្នា មជ្ឈមណ្ឌលកម្ពុជាដើម្បីដោះស្រាយទំនាស់ បានក្លាយជា មជ្ឈមណ្ឌលដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ វិញ ។

បច្ចុប្បន្ន អ្វីៗខុសប្លែកពីមុនច្រើន ហើយប៉ុន្មានឆ្នាំកន្លងទៅ វបសអ សំរេចលទ្ធផលបានច្រើនណាស់ ។ គេទទួលស្គាល់ វបសអ ថាជាវិទ្យាស្ថានស្រាវជ្រាវនាំមុខគេនៅកម្ពុជា ដោយបានផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវដែលមានលក្ខណៈឯករាជ្យ និងគុណភាពខ្ពស់ដល់សាធារណជន និងបានចូលរួមចំណែកយ៉ាងច្រើន ដល់កិច្ចពិភាក្សាខាងគោលនយោបាយសាធារណៈសំខាន់ៗពាក់ព័ន្ធដល់គ្រប់ៗគ្នាដែលធ្វើការងារដើម្បីអភិវឌ្ឍប្រទេសកម្ពុជា ។ ពិតហើយ ដំណើរការមិនមែនសុទ្ធតែរលូនរហូតនោះទេ ពីព្រោះដូចយើងដឹងស្រាប់ កិច្ចប្រឹងប្រែងឈានឱ្យដល់ស្តង់ដារអន្តរជាតិនៅក្នុងបរិបទប្រទេសកំពុងអភិវឌ្ឍន៍ តែងជួបប្រទះនឹងបញ្ហាប្រឈមជាច្រើន ។ ហេតុនេះ ទន្ទឹមនឹងមោទនភាពចំពោះលទ្ធផលសំរេចបាន វបសអ ក៏ដឹងច្បាស់ពីចំនុចខ្សោយរបស់ខ្លួន ហើយប្រឹងប្រែងឥតឈប់ឈររិះរកមធ្យោបាយដើម្បីកែលំអការងារ ។

ជាមតិផ្ទាល់ ខ្ញុំគិតថា ការអភិវឌ្ឍន៍សំខាន់ៗ គួរឱ្យរីករាយបំផុតបានកើតមានឡើងក្នុងរយៈ ២ឆ្នាំចុងក្រោយ ។ ក្រុមប្រឹក្សាភិបាល បានអនុម័តផែនការអភិវឌ្ឍន៍ស្ថាប័ន ដែលនៅពេលអនុវត្តបានពេញលេញទៅ នឹងធ្វើអោយ វបសអ ក្លាយជាវិទ្យាស្ថានស្រាវជ្រាវជំនាញដែលអាចធ្វើការស្មើដៃគ្នាជាមួយវិទ្យាស្ថានណាៗទាំងអស់ក្នុងពិភពលោក ។ នៅក្នុងផែនការ មានការផ្តោតខ្លាំងលើការកសាងសមត្ថភាពអ្នកស្រាវជ្រាវកម្ពុជា ។ នេះជាលើកដំបូងហើយ ដែល វបសអ មានផែនការ និងវចនាសម្ព័ន្ធច្បាស់លាស់ សំរាប់ការអភិវឌ្ឍន៍ចំណេះដឹង និងអាជីពរបស់អ្នកទាំងនេះ ។ នៅពេលពួកគេណែនាំខ្លួនឯងថា ជាអ្នកស្រាវជ្រាវរង រឺអ្នកស្រាវជ្រាវ នៅពេលចូលរួមមតិក្នុងវេទិកាសាធារណៈនានា ខ្ញុំដឹងថា ពួក

តទៅទំព័រទី ១៩

ទស្សនាវដ្ដី
អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១០ លេខ២ ខែមេសា-មិថុនា ឆ្នាំ២០០៦

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ)
ផ្ទះលេខ៥៦ ផ្លូវ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
អាសយដ្ឋានប្រៃសណីយ: ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ ទូរសារ: (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdri@camnet.com.kh / pubs@cdri.forum.org.kh
website: http://www.cdri.org.kh

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដងមួយឆ្នាំជាភាសាខ្មែរ និងអង់គ្លេសនៅក្នុងពេលដំណាលគ្នា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហានៃការអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ *អត្ថបទតាមដានសេដ្ឋកិច្ច* ផ្តល់ជូននូវមូលវិចារឯករាជ្យស្តីពីដំណើរប្រព្រឹត្តទៅនៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិតត្រូវចុះហត្ថលេខាប្រត្យក្សភាព ទូរស័ព្ទ និងមានអាសយដ្ឋានផង ។ អ្នកនិពន្ធទាំងអស់ត្រូវទាក់ទង វបសអ មុននឹងជូនអត្ថបទរបស់ខ្លួន ទោះបីជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសំរាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។

ISBN 99950-52-06-7
9789995052065

គ្រឹះស្ថានផ្សាយ: វបសអ
គ្រប់គ្រងកែសំរួល: យូ សិទ្ធីរិទ្ធ
កែសំរួលផលិតកម្ម: អ៊ុំ ចាន់ថា
រោងពុម្ពជប៉ុន ភ្នំពេញ រូបភាពទំព័រមុខ: រូបភាព CDRI

រក្សាសិទ្ធិ ២០០៦ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៏អក្សរពី វបសអ ឡើយ ។

ISSN 1560-7615 / ISBN 978-99950-52-06-5

ទំនួលខុសត្រូវលើគំនិត សត្យានុម័ត និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា គឺជាបន្ទុកផ្ទាល់របស់អ្នកនិពន្ធ ។
ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ វបសអ ទេ ។